# វគ្គប្រជុំទី 3 អំពីភាគីពាក់ព័ន្ធនឹងច្បាប់ស្ដីពីអាកាសធាតុឆ្នាំ 2024

ថ្ងៃទី 24 ខែមេសា ឆ្នាំ 2025 មហាវិទ្យាល័យសហគមន៍ Roxbury

កិច្ចប្រជុំលក្ខណៈហាយប្រ៊ីដ

# ការរៀបចំសេវាបកប្រែផ្ទាល់មាត់

- ការបកប្រែភាសាផ្ទាល់មាត់ត្រូវបានផ្តល់ជូនជាភាសា៖ EEspañol, Português, Kreyòl ayisyen, Kriolu, Tiếng Việt, 普通话, عربي, русский, ខ្មែរ, 한국어, français និងភាសាសញ្ញាអាមេរិកាំង (ASL)។
  - ដើម្បីចូលរួមជាភាសារអង់គ្លេស រួចចុចរូបតំណាង “Interpretation” (ការបកប្រែផ្ទាល់មាត់) ហើយចុច English (ភាសាអង់គ្លេស)។
  - Para entrar no canal em português, clique no ícone “Interpretation” e selecione “Portuguese”.
  - Si alguien desea interpretación en español, haga clic en “Interpretation” y seleccione “Spanish”.
  - Pou rantre nan chanèl kreyòl ayisyen an, klike sou ikòn “Interpretation” an epi chwazi “Haitian Creole”.
  - Pa partisipa na Kriolu, klika na íkone "Intirpretason" y silisiona "Cape Verdean Kriolu".
  - 要以普通话参加会议，请单击口语图标并选择 "Chinese”.
  - Để vào kênh bằng tiếng Việt, hãy nhấp vào biểu tượng “Interpretation” và chọn “Vietnamese”.
  - للمشاركة باللغة العربية اضغط على أيقونة "الترجمة الفورية" ثم اختر“Arabic“.
  - Чтобы принять участие на Русский языке, нажмите на ярлык «Устный перевод» и выберите “Russian”.
  - ដើម្បីចូលរួមជាភាសាខ្មែរ សូមចុច រូបតំណាងការបកប្រែ ហើយជ្រើសរើសភាសា “Khmer”។
  - 한국어로 참여하려면 "통역" 아이콘을 클릭하고 “Korean"를 선택하세요.
  - Pour participer en français, cliquez sur l’icône « Interprétation » puis choisissez « French ».

- សូមនិយាយយឺតៗ។
- រាល់អ្នកចូលរួមទាំងអស់ត្រូវតែជ្រើសរើសបណ្តាញភាសាមួយ ទោះបីជាមើលបទបង្ហាញជាភាសាអង់គ្លេសក៏ដោយ។



# សូមស្វាគមន៍ពី
# ជម្រើសសម្រាប់សហគមន៍ និងបរិស្ថាន
# (Alternatives for Community & Environment)

ACE
alternatives for
community &
environment
Building Power for Environmental Justice


ការរើសអើងផ្នែកបរិស្ថានមិនមែនជាអ្វីថ្មីទេ
ពូជសាសន៍គឺជាកត្តាព្យាករណ៍ដ៏សំខាន់បំផុតចំពោះអ្នកណាដែលរស់នៅក្បែរខ្យល់ ទឹក ឬដីដែលកខ្វក់
56%
ក្នុងចំណោមប្រជាជននៅជិតកន្លែងសំណល់ពុល គឺជាអ្នកដែលមានមិនមែនជាជនជាតិស្បែកស។
មាន
38%
ការប៉ះពាល់នឹងអាសូត-ឌីអុកស៊ីតកាន់តែខ្ពស់។
គឺ
2x
ទំនងជារស់នៅដោយគ្មានទឹកស្អាត និងបង្គន់អនាម័យទំនើប ។
អ្នកដែលមានមិនមែនជាជនជាតិស្បែកសៈ
បានឃើញ
95%
នៃការទាមទាររបស់ពួកគេទល់នឹងអ្នកបំពុលបរិស្ថានត្រូវបានច្រានចោលដោយទីភ្នាក់ងារការពារបរិស្ថាន (EPA)។
Nation


ភាពអយុត្តិធម៌ផ្នែកបរិស្ថានគឺជារួម
ការបំពុលខ្យល់
ការបង្ក្រាបសំឡេងអ្នកបោះឆ្នោត
ជំងឺបេះដូង
ភាពអយុត្តិធម៌សម្រាប់លំនៅឋាន
ទឹកកខ្វក់
វិសមភាពនៃប្រាក់ចំណូល
ការរើសអើងពូជសាសន៍ជាប្រព័ន្ធ

## រូបភាពទី 7. ជំងឺហឺតក្នុងចំណោមមនុស្សពេញវ័យតាមសង្កាត់ ឆ្នាំ 2017, 2019 និង 2021 រួមបញ្ចូល



## រូបភាពទី 1. ភាពជិតស្និទ្ធនៃគម្រោងផលិតអគ្គិសនីដែលមានស្រាប់ និងដែលបានដាក់ស្នើទៅសង្កាត់យុត្តិធម៌បរិស្ថាន




*ខណៈដែលសង្កាត់យុត្តិធម៌លើផ្នែកបរិស្ថាន (EJ) និងរោងចក្រថាមពលមានទីតាំងនៅទូទាំងរដ្ឋ អង្គភាពផលិតអគ្គិសនីដែលបញ្ចេញផ្សែងបំពុលធំជាងគេដោយវិសមាមាត្រនៅក្នុង ឬនៅក្បែរសង្កាត់យុត្តិធម៌លើផ្នែកបរិស្ថាន (EJ)។ ក្នុងចំណោមគម្រោងថាមពលដែលបានដាក់ស្នើឡើងធំជាង 35 MW រោងចក្រថាមពលដែលបញ្ចេញផ្សែងពុលមួយ (ឧស្ម័នដែលកើតចេញពីចំហេះឥន្ធនៈ) នឹងស្ថិតនៅក្នុងសង្កាត់ផ្នែកបរិស្ថាន (EJ) ដូចគ្នានឹងមួយភាគបីនៃគម្រោងស្តុកថាមពលដែលបានដាក់ស្នើឡើង (ពីរក្នុងចំណោមប្រាំមួយ)។*

*ចំណាំ៖ រង្វង់ទាំងនេះតំណាងឱ្យសមត្ថភាពថាមពលក្នុងមួយទីតាំងដែលប្រមូលផ្តុំដោយប្រេងឥន្ធនៈ/បច្ចេកវិទ្យា។ មិនបានរួមបញ្ចូលទាំងគម្រោងទួរប៊ីនខ្យល់នៅសមុទ្រចំនួនបួនដែលរដ្ឋបានស្នើ និងគម្រោងស្ថានីយ៍ស្តុកទុកដោយអាគុយដែលពាក់ព័ន្ធមួយនោះទេ។*

# តារាងទី 1. ភាពជិតស្និទ្ធនៃអង្គភាពផលិតអគ្គិសនីទៅនឹងសង្កាត់យុត្តិធម៌បរិស្ថាន

| | ប្រភពបញ្ចេញផ្សែងពុល | | | | ប្រភពដែលមិនបញ្ចេញផ្សែងពុល | | | |
|---|---|---|---|---|---|---|---|---|
| | ឧស្ម័ន | ឥន្ធនៈហ្វូស៊ីលផ្សេងទៀត | កាកសំណល់ | ជីវម៉ាស | ពន្លឺព្រះអាទិត្យ | ទួរប៊ីនខ្យល់ | វារីអគ្គិសនី | ឧបករណ៍ផ្ទុក |
| អង្គភាពដែលមានសង្កាត់យុត្តិធម៌លើផ្នែកបរិស្ថាន (EJ) | 60 | 56 | 6 | 1 | 122 | 12 | 57 | 26 |
| អង្គភាពក្នុងរយៈចម្ងាយ 1 ម៉ាយល៍ពីអង្គភាពដែលមានសង្កាត់យុត្តិធម៌លើផ្នែកបរិស្ថាន (EJ) | 33 | 11 | 11 | 55 | 189 | 6 | 14 | 28 |
| ចំនួនអង្គភាពសរុបនៅក្នុងរដ្ឋ | 114 | 77 | 17 | 9 | 598 | 35 | 98 | 96 |
| ភាគរយក្នុង ឬក្នុង 1 ម៉ាយល៍ពីសង្កាត់យុត្តិធម៌ផ្នែកបរិស្ថាន (EJ) | **82%** | **87%** | **100%** | **67%** | **52%** | **51%** | **72%** | **56%** |

*អង្គភាពផលិតអគ្គិសនីដែលបានបញ្ចេញផ្សែងពុលមានទីតាំងវិសមាមាត្រនៅជិតសង្កាត់យុត្តិធម៌បរិស្ថាន៖ 84 ភាគរយស្ថិតនៅក្នុង ឬក្នុងចម្ងាយមួយម៉ាយល៍ពីសង្កាត់អគ្គិសនីសង្កាត់យុត្តិធម៌បរិស្ថាន (EJ) ដែលបង្កើតឡើងតែ 52 ភាគរយនៃក្រុមប្លុកជំរឿននៅក្នុងរដ្ឋប៉ុណ្ណោះ។ ហាសិបប្រាំភាគរយនៃប្រភពដែលមិនបញ្ចេញផ្សែងពុលមានទីតាំងនៅក្នុង ឬនៅក្បែរសង្កាត់សង្កាត់យុត្តិធម៌បរិស្ថាន (EJ)។*

*ចំណាំ៖ កាកសំណល់រួមមានកន្លែងចាក់ឧស្ម័នចោល និងសំណល់រឹងពីទីក្រុង។ ជីវម៉ាស់រួមមានកាកសំណល់ពីការកែច្នៃឈើ និងឈើ ដំណាំកសិកម្ម និងសំណល់ផ្ទះបាយ និងលាមកសត្វ និងសំណល់ទឹកស្អុយពីមនុស្សសម្រាប់ការផលិតជីវឧស្ម័ន។*

# របៀបវារៈនៃកិច្ចប្រជុំថ្ងៃនេះ

- ម៉ោង 5:30៖ ទិដ្ឋភាពទូទៅនៃការបកប្រែផ្ទាល់មាត់
- ម៉ោង 5:40៖ សូមស្វាគមន៍ដោយជម្រើសសម្រាប់សហគមន៍ និងបរិស្ថាន (ACE)
- ម៉ោង 5:45៖ សុន្ទរកថាបើកកិច្ចប្រជុំ – María Belén Power អនុរដ្ឋលេខាធិការនៃយុត្តិធម៌បរិស្ថាន និងសមធម៌ កិច្ចការថាមពល និងបរិស្ថាន (EEA) និង Staci Rubin ស្នងការនៃនាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU)
- ម៉ោង 5:55៖ ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 – Michael Judge អនុរដ្ឋលេខាធិការក្រសួងថាមពល កិច្ចការថាមពល និងបរិស្ថាន (EEA)
- ម៉ោង 6:05៖ បទបង្ហាញរបស់ក្រសួងធនធានថាមពល (DOER) – Rick Collins ជានាយក ផ្នែកកំណត់ទីតាំង និងផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ថាមពលស្អាត ក្រសួង ធនធានថាមពល (DOER)
- ម៉ោង 6:15៖ សំណួរ និងចម្លើយខ្លីៗ
- ម៉ោង 6:20៖ តម្រូវការនៃការចូលរួមជាមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) – Veena Dharmaraj នាយកផ្នែកការចូលរួមសាធារណៈ និងយុត្តិធម៌លើផ្នែកបរិស្ថាន (EJ) របស់នាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU)
- ម៉ោង 6:40៖ សំណួរ និងចម្លើយខ្លីៗ
- ម៉ោង 6:50៖ សុន្ទរកថាដោយ James Van Nostrand ប្រធាននាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU)
- ម៉ោង 7:00៖ កម្មវិធីជំនួយឧបត្ថម្ភអន្តរការីរបស់នាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) និងក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) - Veena Dharmaraj នាយកផ្នែកការចូលរួមសាធារណៈ និងយុត្តិធម៌លើផ្នែកបរិស្ថាន (EJ) របស់នាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU)
- ម៉ោង 7:20៖ សំណួរ និងចម្លើយខ្លីៗ
- ម៉ោង 7:25៖ សម្រាក
- ម៉ោង 7:40៖ គោលការណ៍ណែនាំអំពីគម្រោងអត្ថប្រយោជន៍សហគមន៍ – María Belén Power, អនុរដ្ឋលេខាធិការផ្នែកយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន កិច្ចការថាមពល និងបរិស្ថាន (EEA) និង Crystal Johnson ជំនួយការលេខាធិការនៃយុត្តិធម៌លើផ្នែកបរិស្ថាន (EJ) ការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន កិច្ចការថាមពល និងបរិស្ថាន (EEA)
- ម៉ោង 8:05៖ សំណួរ និងចម្លើយទូទៅ
- ម៉ោង 8:25៖ វគ្គសម្រាប់ភាគីពាក់ព័ន្ធនាពេលខាងមុខ និងសុន្ទរកថាបិទបញ្ចប់

# ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)

- ពង្រាងសំណើ/វគ្គប្រជុំជាមួយភាគីពាក់ព័ន្ធ – **នានិទាឃរដូវឆ្នាំ 2025**
- សវនាការសាធារណៈស្ដីពីបទប្បញ្ញត្តិដែលបានស្នើឡើង – **រដូវស្លឹកឈើជ្រុះឆ្នាំ 2025**
- ការប្រកាសឱ្យអនុវត្តបទប្បញ្ញត្តិ និងការណែនាំ – **ឆ្នាំ 2025 ដល់ដើមឆ្នាំ 2026**
- បទប្បញ្ញត្តិថ្មីៗ – **ថ្ងៃទី 1 ខែមីនា ឆ្នាំ 2026**
- ការដាក់សំណើសុំថ្មីៗ – **ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026**

# តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពលជាអ្វី?

- ក្រុមប្រឹក្សាឯករាជ្យមួយ ត្រូវបានបង្កើតឡើងប្រហែល 50 ឆ្នាំមុន (អតីតក្រុមប្រឹក្សានៃការកំណត់ទីតាំងបរិក្ខាផលិតថាមពល (EFSC))
- មានសមាជិកចំនួនប្រាំបួននាក់៖ សមាជិកដែលមានមុខដំណែងចំនួនប្រាំមួយនាក់ និងសមាជិកសាធារណៈចំនួនបីនាក់ ដែលដឹកនាំដោយរដ្ឋលេខាធិការក្រសួងថាមពល និងបរិស្ថាន។
    - យុត្តាធិការរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងមានចំពោះបរិក្ខារផលិតថាមពលធំៗដែលកំណត់ដោយលក្ខន្តិកៈ៖
        - បរិក្ខារផលិតថាមពលស្មើ ឬច្រើនជាង 100 MW និងរចនាសម្ព័ន្ធបន្ថែម (កម្រិតកំណត់នេះត្រូវបានកាត់បន្ថយដល់ 25 MW នៅក្នុងច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024)
        - បណ្តាញបញ្ជូនចរន្តអគ្គិសនី
            - សម្រាប់ច្រករបៀងថ្មី៖ ≥ 69 kV **និង** ≥ប្រវែង 1 ម៉ាយល៍
            - ច្រករបៀងដែលមានស្រាប់៖ ≥ 115 kV **និង** ≥ប្រវែង 10 ម៉ាយល៍ លើកលែងតែការបញ្ជូនឡើងវិញ ឬការសាងសង់ឡើងវិញក្នុងកម្រិតតង់ស្យុងដូចគ្នា
        - បណ្តាញទុយយោបង្ហូរឧស្ម័ននៅក្នុងរដ្ឋលើសពី 100 psig **និង**ប្រវែងលើសមួយម៉ាយល៍ លើកលែងតែការសាងសង់ឡើងវិញ ឬការតម្លើងទុយយោបង្ហូរឧស្ម័នដែលមានស្រាប់
        - កន្លែងផ្ទុកឧស្ម័ន (ឧស្ម័នធម្មជាតិរាវ (LNG) ឬឧស្ម័នធម្មជាតិដែលបានបង្ហាប់ (CNG)) លើសពី 25,000 ហ្គាឡុង
        - កន្លែងផ្ទុក/ទុយយោបង្ហូរប្រេងដែលមានប្រវែងជាង 1 ម៉ាយល៍ ធុងផ្ទុកថ្មីលើស 500,000 បារ៉ែល
- ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងរៀបចំដំណើរការនីតិវិធីវិនិច្ឆ័យ ចេញសេចក្តីសម្រេចលើការដាក់ញត្តិដើម្បីសាងសង់ និងបញ្ជាក់ពីផលប៉ះពាល់បរិស្ថាន និងផលប្រយោជន៍សាធារណៈ សម្រាប់ទីតាំងនៅក្រោមយុត្តាធិការ ក៏ដូចជាការអនុវត្តសិទ្ធិអំណាចលើការលើកលែងពីការកំណត់តំបន់។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងអាចត្រូវបានដាក់បណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។
- ផ្នែកកំណត់ទីតាំងរបស់នាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) បម្រើការងារជាបុគ្គលិករបស់ស្ទួងការនាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) និងក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)

# បទប្បញ្ញត្តិស្ដីពីការកំណត់ទីតាំង និងការអនុញ្ញាតសំខាន់ៗនៃច្បាប់ស្ដីពីអាកាសធាតុឆ្នាំ 2024

- ពង្រីកក្រុមប្រឹក្សាកំណត់ទីតាំងពីសមាជិកចំនួនប្រាំបួនទៅដប់មួយនាក់ ដោយបង្កើតអាណត្តិថ្មី វិសាលភាពនៃការពិនិត្យវាយតម្លៃ និងលទ្ធផលដែលតម្រូវឱ្យមាន។
- បង្កើតប្រភេទហេដ្ឋារចនាសម្ព័ន្ធថ្មី៖ ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF)។
- បង្កើតកម្មវិធីអនុញ្ញាតរួមបញ្ចូលកម្មវិធីទាំងពីរ។
  - ការអនុញ្ញាតរួមគឺជាការអនុញ្ញាតមួយដែលរួមបញ្ចូលទាំងការអនុញ្ញាតរបស់រដ្ឋ តំបន់ និងមូលដ្ឋានទាំងអស់ ដែលនឹងត្រូវការដើម្បីសាងសង់ និងដំណើរការហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF)។ និយមន័យនេះមិនរាប់បញ្ចូលការអនុញ្ញាតសហព័ន្ធមួយចំនួននោះទេ។
    - ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF) ទ្រង់ទ្រាយធំ - ការអនុញ្ញាតរួមដែលត្រូវផ្ដល់ដោយក្រុមប្រឹក្សាកំណត់ទីតាំង។
    - ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF) ទ្រង់ទ្រាយតូច - ការអនុញ្ញាតរួមក្នុងតំបន់ដែលត្រូវផ្ដល់ដោយអាជ្ញាធរក្រុង។
- ផ្ដល់កាលបរិច្ឆេទកំណត់សម្រាប់ការពិនិត្យ CEIF ឡើងវិញ និងការអនុម័តលើការសាងសង់ ប្រសិនបើមិនបានបំពេញតាមកាលបរិច្ឆេទកំណត់ទេនោះ។
- បង្កើតលក្ខខណ្ឌតម្រូវថ្មីៗសម្រាប់អ្នកដាក់ពាក្យស្នើសុំហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF) រួមមាន៖
  - ការប្រឹក្សាយោបល់ និងការចូលរួមមុនការដាក់ឯកសារស្នើសុំ។
  - ការវាយតម្លៃផលប៉ះពាល់សរុប (CIA) (តម្រូវឱ្យមានផងដែរនូវការវាយតម្លៃដែលមិនមែនជា ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF))។
- ប្ដូរយុត្តាធិការកំណត់ទីតាំងរបស់ក្រសួងសេវាសាធារណៈមួយចំនួនទៅជាការទទួលខុសត្រូវកំណត់ទីតាំងរួមរបស់ក្រុមប្រឹក្សាកំណត់ទីតាំង។

# លក្ខខណ្ឌតម្រូវថ្មីៗសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង

- កែសម្រួលសមាជិកភាពនៃក្រុមប្រឹក្សាកំណត់ទីតាំង។ ជំពូកនៃច្បាប់ទូទៅ 164, § 69H។
  - បន្ថែមមុខតំណែងថ្មីចំនួនពីរ – ក្រសួងជលផល និងរុក្ខាប្រមាញ់ និងក្រសួងសុខភាពសាធារណៈ (និងកាត់បន្ថយក្រសួងសាធារណៈមកត្រឹមមួយអាសនៈ)។
  - បង្កើនចំនួនអាសនៈសម្រាប់សមាជិកសាធារណៈពីបីទៅបួនអាសនៈ៖ រដ្ឋ Mass។ សមាគមទីភ្នាក់ងាររៀបចំផែនការក្នុងតំបន់ រដ្ឋ Mass។ សមាគមក្រុងនៃរដ្ឋ Mass ផ្នែកយុត្តិធម៌បរិស្ថាន/អធិបតេយ្យភាពជនជាតិដើមភាគតិច និងកម្លាំងពលកម្ម (និងលុបចោលសមាជិកសាធារណៈដែលតំណាងឱ្យថាមពល និងបរិស្ថាន)។
- ពង្រីកយុត្តាធិការរបស់ក្រុមប្រឹក្សាកំណត់ទីតាំង។ ឧទាហរណ៍ បន្ថែមយុត្តាធិការលើប្រព័ន្ធផ្ទុកថាមពលថ្ម។
- បង្កើតប្រភេទថ្មី និងច្បាប់វិធានថ្មីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF)។
- បង្កើតដំណើរការថ្មីសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំងដើម្បីចេញលិខិតអនុញ្ញាតរួម។

# លក្ខខណ្ឌតម្រូវថ្មីៗសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង (ត)

- កំណត់អាណត្តិផ្លូវច្បាប់ថ្មី និងវិសាលភាពនៃការពិនិត្យវាយតម្លៃសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង។
  - ក្រុមប្រឹក្សាកំណត់ទីតាំងកំពុងតែកំណត់ថា តើគម្រោងមួយនឹងផ្តល់នូវការផ្គត់ផ្គង់ថាមពលដែលអាចជឿជាក់បាន ដោយមានផលប៉ះពាល់ដល់បរិស្ថានជាអប្បបរមា និងមានតម្លៃតិចបំផុតដែរឬទេ។
  - ស្ថិតក្រោមច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 នៅពេលពិនិត្យមើលគម្រោងដែលបានស្នើឡើង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងត្រូវតែពិចារណាចំណុចផ្សេងរួមមានទាំង បន្ទុកជារួមលើសហគមន៍ដែលជាម្ចាស់ផ្ទះ ផលប៉ះពាល់សុខភាពសាធារណៈ និងផលប៉ះពាល់លើការប្រែប្រួលអាកាសធាតុ។ ច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 ក៏រួមមានបញ្ញើលទ្ធផល ដែលក្រុមប្រឹក្សាកំណត់ទីតាំងត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួនលើគម្រោងដែលបានស្នើឡើងផងដែរ។
- បន្ថែមកាលបរិច្ឆេទកំណត់តាមច្បាប់សម្រាប់ការពិនិត្យវាយតម្លៃរបស់ក្រុមប្រឹក្សាកំណត់ទីតាំងទៅលើហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF) ដែលបានស្នើឡើង។
  - ប្រសិនបើក្រុមប្រឹក្សាកំណត់ទីតាំងមិនចេញសេចក្តីសម្រេចត្រឹមថ្ងៃកំណត់ដែលបានតម្រូវ (មិនលើសពីរយៈពេល 15 ខែ) ទេ នោះគម្រោងនឹងត្រូវបានអនុម័តលើការសាងសង់ ហើយទទួលបានការអនុញ្ញាតរួមដោយមានលក្ខខណ្ឌស្តង់ដា។
- លក្ខខណ្ឌតម្រូវបន្ថែម
  - ការបង្កើតផ្ទាំងគ្រប់គ្រង
  - ក្រុមប្រឹក្សាកំណត់ទីតាំងត្រូវជួបប្រជុំនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាកំណត់ទីតាំងជាសាធារណៈតាមបែបហាយប្រ៊ីដ
  - ការដាក់សំណើសុំស្តង់ដាធម្មតា

# តម្រូវការថាមពលស្អាតនៅក្នុងរដ្ឋ Massachusetts

ថាមពលដែលផលិតដោយទួរប៊ីនខ្យល់ **180 MW** ត្រឹមឆ្នាំ 2025
**4,470 MW** នៃថាមពលពីពន្លឺព្រះអាទិត្យជាចរន្តឆ្លាស់ត្រឹមឆ្នាំ 2025

**3,650 MW** នៃថាមពលដែលផលិតដោយទួរប៊ីនខ្យល់ត្រឹមឆ្នាំ 2030
**8,360 MW** នៃថាមពលពីពន្លឺព្រះអាទិត្យជាចរន្តឆ្លាស់ត្រឹមឆ្នាំ 2030

**24 GW** នៃថាមពលដែលផលិតដោយទួរប៊ីនខ្យល់ត្រឹមឆ្នាំ 2050
**27+ GW** នៃថាមពលពីពន្លឺព្រះអាទិត្យជាចរន្តឆ្លាស់ត្រឹមឆ្នាំ 2050

**សមត្ថភាពក្នុងការផលិតអគ្គិសនីកើតឡើងវិញនៅក្នុងរដ្ឋ**
**113 MW** នៃសម្ថភាពក្នុងការផលិតដោយទួរប៊ីនខ្យល់ក្នុងឆ្នាំ 2022
**3,325 MW** នៃសមត្ថភាពថាមពលពីពន្លឺព្រះអាទិត្យជាចរន្តឆ្លាស់ក្នុងឆ្នាំ 2022

**ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG)**
ការបំភាយឧស្ម័ននៅកម្រិត**សូន្យ**ត្រឹមឆ្នាំ 2050

ឆ្នាំ 2021 · ឆ្នាំ 2022 · ឆ្នាំ 2023 · ត្រឹមឆ្នាំ 2025 · ត្រឹមឆ្នាំ 2030 · ត្រឹមឆ្នាំ 2050

**សមត្ថភាពផ្ទុកថាមពល**
**550 MWh** នៃការផ្ទុកថាមពលដែលបានដំឡើងគិតត្រឹមថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2023

គោលដៅនៃការផ្ទុកថាមពលក្នុងទំហំ **1,000 MWh** ត្រឹមឆ្នាំ 2025

**បន្ទុកអគ្គិសនី**
ត្រឹមឆ្នាំ 2035 ទំនងជាមានការកើនឡើងដល់ 50% បើធៀបនឹងសព្វថ្ងៃ (60 GWh ដល់ទំហំ 90+ GWh)

ទំហំផ្ទុក **5.8 GW** ត្រឹមឆ្នាំ 2050

# បញ្ហាប្រឈមជាមួយនឹងនីតិវិធីអនុញ្ញាតដែលមានស្រាប់

- ដំណើរការអនុញ្ញាតដែលមានរយៈពេលយូរ មិនអាចព្យាករជាមុនបាន និងជួនកាលមានលក្ខណៈស្មុគស្មាញដដែលៗ។
  - ពេលវេលាកំណត់មានភាពខុសគ្នាខ្លាំង ហើយគម្រោងមួយចំនួនបានចំណាយពេលរហូតដល់មួយទសវត្សរ៍ដើម្បីបញ្ចប់។
  - តាមប្រវត្តិពីដើមមក ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) បានចំណាយពេលចន្លោះពី 1 ដល់ 4 ឆ្នាំ ដើម្បីផ្តល់ការអនុញ្ញាតឱ្យដល់ការសាងសង់ បន្ទាប់ពីរយៈពេលនោះ គម្រោងនៅតែត្រូវការលិខិតអនុញ្ញាតក្នុងមូលដ្ឋានផ្សេងៗគ្នា និងពីរដ្ឋទាំងអស់។
- ឱកាសសម្រាប់បណ្តឹងឧទ្ធរណ៍លើលិខិតអនុញ្ញាតដាច់ដោយឡែកនីមួយៗអាចបណ្តាលឱ្យមានការពន្យារពេលជាច្រើនឆ្នាំ។
- អ្នកនៅក្នុងសហគមន៍មានអារម្មណ៍ថា ជាញឹកញាប់ពួកគេមិនបានផ្តល់មតិយោបល់គ្រប់គ្រាន់ ឬប្រកបដោយឥទ្ធិពលទៅក្នុងការកំណត់ទីតាំងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំនោះទេ។
- អ្នកនៅក្នុងសហគមន៍អាចនិងមិនមានធនធានចាំបាច់ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការអនុញ្ញាតទេ។
- **រដ្ឋ Massachusetts នឹងមិនបំពេញតាមផែនកំណត់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) របស់យើងដោយគ្មានការកែទម្រង់ទេ។**

# គណៈកម្មការទទួលបន្ទុកការកំណត់ទីតាំង និងការអនុញ្ញាតសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថាមពល

- ស្ទងការត្រូវបានបង្កើតឡើងតាមបទបញ្ញាប្រតិបត្តិលេខ 620
- តម្រូវឱ្យផ្ដល់ដំបូន្មានដល់អភិបាលស្ដីពី៖
  1. **ការពន្លឿនការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតប្រកបដោយភាពប្រុងប្រយ័ត្នតាមរយៈការកំណត់ទីតាំង និងការអនុញ្ញាតដែលមានការកែទម្រង់**តាមលក្ខណៈដែលអនុលោមតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ជាធរមាន និងផែនការថាមពលស្អាត និងអាកាសធាតុ។
  2. **ការសម្រួលសម្រួលឱ្យមានការផ្ដល់មតិយោបល់ពីសហគមន៍** ទៅលើការកំណត់ទីតាំង និងការអនុញ្ញាតចំពោះហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត និង
  3. **ការធានាថាអត្ថប្រយោជន៍ពីការផ្លាស់ប្ដូរទៅប្រើថាមពលស្អាតត្រូវបានចែករំលែកប្រកបដោយសមភាព**ក្នុងចំណោមប្រជាជនរស់នៅ Commonwealth។
- វគ្គនៃកិច្ចប្រជុំដោយស្ដាប់មតិសាធារណៈចំនួនពីរដែលបានធ្វើឡើង ហើយទទួលបានមតិសាធារណៈជាង 1,500 មតិ។
- ការណែនាំដែលបានផ្ញើជូនអភិបាល Healey កាលពីថ្ងៃទី 29 ខែមីនា ឆ្នាំ 2024។
- ការណែនាំរបស់ស្ទងការត្រូវបានទទួលយកជាផ្លូវការយ៉ាងទូលំទូលាយដោយត្រូវបានអនុវត្តជាច្បាប់តាមរយៈ *ច្បាប់ស្ដីពីការលើកកម្ពស់បណ្ដាញថាមពលស្អាត ការលើកកម្ពស់សមភាព និងការការពារអ្នកបង់ថ្លៃថាមពលប្រើប្រាស់* (ច្បាប់ស្ដីពីអាកាសធាតុឆ្នាំ 2024) ដែលត្រូវបានចុះហត្ថលេខាដោយអភិបាល Healey កាលពីខែវិច្ឆិកា ឆ្នាំ 2024។

# ការអនុញ្ញាតរួមរបស់រដ្ឋ

- រាល់លិខិតអនុញ្ញាតក្នុងមូលដ្ឋាន តំបន់ និងរដ្ឋទាំងអស់សម្រាប់បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយធំ ដែលត្រូវបានរួមបញ្ចូលទៅក្នុង**ការអនុញ្ញាតរួមមួយ** ដែលចេញដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងផលិតថាមពល (EFSB)។
- រាល់ទីភ្នាក់ងារប្រចាំរដ្ឋ និងមូលដ្ឋានទាំងអស់ដែលនឹងមានតួនាទីផ្តល់ការអនុញ្ញាតផ្សេងទៀតអាច**ធ្វើអន្តរាគមន៍ និងចូលរួមដោយស្វ័យប្រវត្តិ**តាមរយៈការចេញសេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌអនុញ្ញាតដូចបានផ្តល់ការណែនាំ។
- រាល់គម្រោងទាំងអស់ត្រូវតែដាក់បញ្ជូនការវិភាគផលប៉ះពាល់សរុបដែលជាផ្នែកនៃការដាក់ពាក្យសុំទៅកាន់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)។
- សេចក្តីសម្រេចលើការអនុញ្ញាតត្រូវតែចេញក្នុងរយៈពេល**ហោចណាស់រយៈពេលជាង 15 ខែ**ចាប់ពីការកំណត់ភាពពេញលេញនៃការដាក់ពាក្យសុំ។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) អាចដាក់បណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។



- អនុវត្តចំពោះកន្លែងផលិតថាមពលទំហំ >25 MW កន្លែងផ្ទុកថាមពលទំហំ >100 MWh ហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងទួរប៊ីនខ្យល់នៅឯនាយសមុទ្រ និងគម្រោងបញ្ជូនថាមពលថ្មីទ្រង់ទ្រាយធំ

# ការអនុញ្ញាតក្នុងតំបន់រួម

- រដ្ឋាភិបាលក្នុងមូលដ្ឋាន (អាជ្ញាធរក្រុង និងស្ថង់ការប្រចាំតំបន់ដូចជាស្ថង ការនៅ Cape Cod និង Martha's Vineyard ជាដើម) **រក្សាអំណាចផ្តល់ការអនុញ្ញាតទាំងអស់សម្រាប់គម្រោងដែលមិនស្ថិតក្រោមការពិនិត្យដោយ EFSB**។
- រដ្ឋាភិបាលក្នុងមូលដ្ឋាន**អាចបន្តដំណើរការអនុម័តដាច់ដោយឡែក**ក្នុងពេលដំណាលគ្នា (ឧទាហរណ៍ តំបន់ដីសើម ការកំណត់តំបន់ ជាដើម) ប៉ុន្តែត្រូវបានតម្រូវឱ្យ**ចេញការអនុញ្ញាតតែមួយ**ដែលរួមបញ្ចូលការអនុម័តជាលក្ខណៈបុគ្គលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។
- សេចក្តីសម្រេចលើការអនុញ្ញាតត្រូវតែចេញ**ក្នុងរយៈពេល 12 ខែ**។
- រដ្ឋាភិបាលក្នុងមូលដ្ឋានអាចបញ្ជូនការពិនិត្យវាតម្លៃដើម្បីផ្តល់ការអនុញ្ញាតដោយផ្ទាល់ទៅកាន់ EFSB ប្រសិនបើពួកគេមិនមានធនធានគ្រប់គ្រាន់។
- ការដាក់ពាក្យសុំការអនុញ្ញាតក៏អាចត្រូវពិនិត្យវាយតម្លៃដោយ EFSB បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋាភិបាលក្នុងមូលដ្ឋាន ប្រសិនបើការពិនិត្យវាយតម្លៃត្រូវបានស្នើសុំដោយភាគីដែលអាចបង្ហាញថា ពួកគេទទួលរងផលប៉ះពាល់យ៉ាងខ្លាំង និងយ៉ាងជាក់លាក់ដោយការសម្រេចចិត្ត បន្ទាប់មកប្តឹងឧទ្ធរណ៍បន្ថែមទៀតដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។
- ក្រសួង DOER ទទួលខុសត្រូវ**ក្នុងការបង្កើតពាក្យសុំការអនុញ្ញាតស្តង់ដាររបស់អាជ្ញាធរក្រុង និងបណ្តុំរួមនៃស្តង់ដាសុខភាព សុវត្ថិភាព និងបរិស្ថានកម្រិតមូលដ្ឋាន** ដែលត្រូវប្រើដោយអ្នកធ្វើការសម្រេចចិត្តក្នុងមូលដ្ឋាននៅពេលអនុញ្ញាតឱ្យមានហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។



- អនុវត្តចំពោះគ្រឿងបរិក្ខារផលិតថាមពលទំហំ <25 MW គ្រឿងបរិក្ខារផ្ទុកថាមពលទំហំ <100 MWh និងគម្រោងបញ្ជូនចរន្ត និងចែកចាយថាមពលដែលមិនមែនក្នុងដែនសមត្ថកិច្ចរបស់ EFSB

# ការចូលរួមពីសហគមន៍កាន់តែមានអត្ថន័យ និងយុត្តិធម៌

- ការបង្កើតការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថានជាផ្លូវការទៅតាមលក្ខន្តិកៈដែលមានអាណត្តិជាក់លាក់ ដើម្បីបង្កើតការណែនាំទាក់ទងនឹងកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ និងការវិភាគផលប៉ះពាល់រួម។

- លក្ខខណ្ឌតម្រូវនៃការចូលរួមជាចាំបាច់របស់សហគមន៍ជាលើកដំបូង រួមបញ្ចូលទាំងការចងក្រងឯកសារអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីចូលរួមជាមួយអង្គការក្នុងសហគមន៍ និងការបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍។

- ផ្នែកការចូលរួមជាសាធារណៈថ្មីនៅនាយកដ្ឋាន DPU ដើម្បីជួយដល់សហគមន៍ និងអ្នកដាក់ពាក្យស្នើសុំគម្រោង ចំពោះសំណួរនានាអំពីការចូលរួម និងដំណើរការនៃនីតិវិធីរបស់នាយកដ្ឋាន DPU និង EFSB។

- ផ្នែកថ្មីខាងជ្រើសរើសទីតាំង និងផ្តល់ការអនុញ្ញាតនៅក្រសួង DOER ដើម្បីជួយដល់សំណួរនានាអំពីការចូលរួម និងដំណើរការក្នុងការផ្តល់ការអនុញ្ញាតក្នុងមូលដ្ឋានសម្រាប់សហគមន៍ និងអ្នកដាក់ពាក្យស្នើសុំគម្រោង។

- ជំនួយហិរញ្ញវត្ថុរបស់អន្តរការីមានសម្រាប់អង្គភាពដែលខ្វះខាតធនធាន ដែលចង់ចូលរួមក្នុងដំណើរការនីតិវិធីរបស់ EFSB ហើយត្រូវបានផ្តល់ឋានៈជាអន្តរការី។ អាជ្ញាធរក្រុងដែលមានប្រជាជនចំនួន 7,500 នាក់ ឬតិចជាងនេះមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុដោយស្វ័យប្រវត្តិ។

# កំណែទម្រង់បន្ថែម

- EEA តម្រូវឱ្យបង្កើតវិធីសាស្ត្រ និងការណែនាំអំពីភាពសមស្របនៃទីតាំង ដើម្បីជូនដំណឹងដល់ដំណើរការនៃការអនុញ្ញាតរបស់រដ្ឋ និងមូលដ្ឋានអំពីភាពសមស្របនៃទីតាំងសម្រាប់ការអភិវឌ្ឍថាមពលស្អាត និងជួយអ្នកអភិវឌ្ឍ ដើម្បីបញ្ចៀស កាត់បន្ថយ និងបន្ធូរបន្ថយផលប៉ះពាល់បរិស្ថាន។
- អាសនៈថ្មីចំនួនប្រាំនៅក្នុងក្រុមប្រឹក្សាភិបាល EFSB៖
  - ស្នងការរបស់នាយកដ្ឋានជលផល និងរុក្ខាប្រមាញ់
  - ស្នងការផ្នែកសុខភាពសាធារណៈ
  - អ្នកតំណាងនៃសមាគមអាជ្ញាធរក្រុងក្នុងរដ្ឋ Massachusetts
  - អ្នកតំណាងនៃសមាគមក្នុងរដ្ឋ Massachusetts របស់សមាគមរៀបចំផែនការប្រចាំតំបន់ និង
  - អ្នកតំណាងដែលមានជំនាញខាងយុត្តិធម៌លើផ្នែកបរិស្ថាន និង/ឬអធិបតេយ្យភាពជនជាតិរបស់ដើមភាគតិច។
- ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតនៅក្រោមយុត្តាធិការរបស់ EFSB ត្រូវបានលើកលែងចេញពីការពិនិត្យដោយច្បាប់ស្ដីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA)។
- អាជ្ញាធរមានសមត្ថកិច្ចក្នុងការកំណត់ទីតាំងនាយកដ្ឋាន DPU ពីដើមមក (ឧទាហរណ៍ ការអនុញ្ញាតឱ្យកំណត់តំបន់ទូទៅ និងសិទ្ធិយកដីមកប្រើសម្រាប់ការបញ្ជូនថាមពល និងបណ្ដាញទុយយោ) ត្រូវបានផ្ទេរទៅកាន់ EFSB។

# តួនាទី និងទំនួលខុសត្រូវ

- មានចរន្តការងារចំនួនប្រាំដែលកើតចេញច្បាប់ ដែលកំពុងអនុវត្តដោយទីភ្នាក់ងារបីផ្សេងគ្នាគឺការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EEA) នាយកដ្ឋាននៃការចូលរួមជាសាធារណៈ (DPU) និងក្រសួងធនធានថាមពល (DOER)
- ភាគច្រើននៃចរន្តការងារទាំងនេះទាក់ទងគ្នាតាមរបៀបមួយចំនួន ប៉ុន្តែទីភ្នាក់ងារនីមួយៗបម្រើគោលបំណងដាច់ដោយឡែកពីគ្នា ហើយបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាក់លាក់
- ទីភ្នាក់ងារទាំងបីមានការប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយគ្នា
- ទីភ្នាក់ងាររដ្ឋផ្សេងទៀតដែលមានតួនាទីក្នុងការអនុញ្ញាតខាងថាមពលសំខាន់ៗក៏ទទួលបានការពិគ្រោះយោបល់ផងដែរ ខណៈដែលសំណើត្រូវបានបង្កើតឡើង



# ជំហានបន្ទាប់

- បទប្បញ្ញត្តិនេះត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី 1 ខែ មីនា ឆ្នាំ 2026។
  - ថវិកា FY25 បន្ថែមរបស់អភិបាលដែលបានដាក់នៅថ្ងៃទី2 ខែមេសាស្នើឱ្យពន្យារកាលកំណត់នេះរហូតដល់ថ្ងៃទី 1 ខែឧសភា ឆ្នាំ 2026។
- EEA, DPU និង EFSB បានកំណត់ពេលប្រជុំភាគីពាក់ព័ន្ធចំនួនបួនលើកសម្រាប់ខែមេសា និងខែឧសភា ហើយកំពុងបញ្ចេញពង្រាងសំណើលើប្រធានបទជាក់លាក់មុនកិច្ចប្រជុំទាំងនេះ។
- ពង្រាងបទប្បញ្ញត្តិនេះនឹងត្រូវបានចេញផ្សាយសម្រាប់មតិសាធារណៈ ប្រហែលនៅចុងរដូវក្តៅ/ដើមរដូវស្លឹកឈើជ្រុះ។
- ក្រសួង DOER និង DPU កំពុងរើសបុគ្គលិកថ្មី។
- ព័ត៌មានបន្ថែមអំពីដំណើរការអាចរកបាននៅលើគេហទំព័រ៖ www.mass.gov/energypermitting
- អ្នកអាចបញ្ជូនសំណួរទៅអាសយដ្ឋានអ៊ីមែល energypermitting@mass.gov

# បេសកកម្មរបស់យើង

## បេសកកម្មរបស់ DOER គឺដើម្បីបង្កើតអនាគតប្រកបដោយថាមពលស្អាត មានតម្លៃសមរម្យ មានភាពធន់ និងគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់រូបនៅក្នុង Commonwealth។

**យើងជានរណា៖** ក្នុងនាមជាការិយាល័យថាមពលរដ្ឋ DOER គឺជាទីភ្នាក់ងារគោលនយោបាយថាមពលជាមូលដ្ឋានសម្រាប់ Commonwealth។ DOER គាំទ្រដល់គោលដៅថាមពលស្អាតរបស់ Commonwealth ជាផ្នែកមួយនៃការឆ្លើយតបគ្រប់ជ្រុងជ្រោយទៅនឹងការគំរាមកំហែងពីការផ្លាស់ប្តូរអាកាសធាតុ។ DOER ផ្តោតលើការផ្លាស់ប្តូរការផ្គត់ផ្គង់ថាមពលរបស់យើងទៅការបំពុលបរិស្ថាន និងការចំណាយតិចជាងមុន ការកាត់បន្ថយ និងកែច្នៃតម្រូវការថាមពល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធថាមពលរបស់យើង។

**អ្វីដែលយើងធ្វើ៖** ដើម្បីបំពេញតាមគោលដៅរបស់យើង DOER បានតភ្ជាប់ និងសហការជាមួយភាគីពាក់ព័ន្ធក្នុងវិស័យថាមពលដើម្បីបង្កើតគោនយោបាយប្រកបដោយប្រសិទភាព។ DOER អនុវត្តគោលនយោបាយនេះតាមរយៈការធ្វើផែនការ បទប្បញ្ញត្តិ និងការផ្តល់មូលនិធិ។ DOER ផ្តល់ឧបករណ៍ដល់បុគ្គល អង្គការ និងសហគមន៍ដើម្បីគាំទ្រដល់គោលដៅថាមពលស្អាតរបស់ពួកគេ។ DOER បានប្តេជ្ញាចិត្តចំពោះតម្លាភាព និងការអប់រំ ដោយគាំទ្រការទទួលបានព័ត៌មាន និងចំណេះដឹងអំពីថាមពល។



**យើងគឺជាទីភ្នាក់ងារ**

របស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពល និងបរិស្ថាន (EEA)។



MASSACHUSETTS DEPARTMENT OF ENERGY RESOURCES

# ទំនួលខុសត្រូវក្នុងការអនុញ្ញាត និងការកំណត់ទីតាំងរោងចក្រថាមពលស្អាត

## ច្បាប់អាកាសធាតុឆ្នាំ 2024 នៅផ្នែកស្តីពីការកំណត់ទីតាំង និងការអនុញ្ញាតបានបង្រួបបង្រួមការពិនិត្យវាយតម្លៃ និងដំណើរការអនុម័តការអនុញ្ញាតនៅកម្រិតរដ្ឋ និងក្នុងតំបន់



### គម្រោងខ្នាតធំ - ក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល (EFSB)

- **លិខិតអនុញ្ញាតតែមួយរួមគ្នា**ពី ESFB ជំនួសឱ្យលិខិតអនុញ្ញាតពីរដ្ឋ តំបន់ និងកម្រិតមូលដ្ឋានជាច្រើន
- សេចក្តីសម្រេច**ក្នុងរយៈពេល 15 ខែ**



### គម្រោងខ្នាតតូច - សាលាក្រុង

- **លិខិតអនុញ្ញាតតែមួយរួមគ្នាពីអង្គភាពសាលាក្រុង** ជំនួសឱ្យលិខិតអនុញ្ញាតកម្រិតមូលដ្ឋានជាច្រើន
- សេចក្តីសម្រេច**ក្នុងរយៈពេល 12 ខែ**

# តួនាទីរបស់ DOER

**ច្បាប់នេះបានបង្កើតតួនាទីថ្មី – និងផ្នែកការងារថ្មី – សម្រាប់ក្រសួង DOER ដើម្បីគាំទ្រដំណើរការកំណត់ទីតាំងរោងចក្រថាមពលក្នុងតំបន់ និងការអនុញ្ញាតឱ្យមានហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតតូចៗ។**

នាយកដ្ឋានកំណត់ទីតាំងរោងចក្រថាមពល និងអនុញ្ញាតថាមពលស្អាតនឹងបង្កើតបទប្បញ្ញត្តិ និងផ្តល់ការគាំទ្របច្ចេកទេស និងជំនួយដល់ក្រុង អ្នកស្នើគម្រោង និងភាគីពាក់ព័ន្ធផ្សេងទៀត។

នៅក្នុងបទប្បញ្ញត្តិរបស់ DOER តម្រូវឱ្យបង្កើត៖

- ស្តង់ដាសុខភាពសាធារណៈ សុវត្ថិភាព និងបរិស្ថាន
- ***ការដាក់ពាក្យស្នើសុំស្តង់ដាទូទៅ***
- លក្ខខណ្ឌតម្រូវនៃការដាក់ឯកសារជាមុន
- ស្តង់ដាសម្រាប់ការអនុវត្តការណែនាំអំពីភាពសមស្របនៃទីតាំង
- លិខិតអនុញ្ញាតរួម
- ការណែនាំសម្រាប់នីតិវិធី/ ពេលវេលាកំណត់
- គូភាគីទទួលខុសត្រូវចំពោះការអនុវត្ត
- ដំណើរការបង់ថ្លៃសេវាក្រុងសម្រាប់សំណងលើការកាត់បន្ថយផលប៉ះពាល់បរិស្ថាន (មិនតម្រូវទេ)
- វិធាន និងលក្ខខណ្ឌតម្រូវទូទៅ

# បន្ទាត់ពេលវេលាឆ្នាំ 2025

ការកំណត់ទីតាំង និងការអនុញ្ញាតរបស់ DOER នៅឆ្នាំ 2025 នឹងមានបីដំណាក់កាល៖

**01**

### ការកំណត់ផ្នែកការងារថ្មី

**រដូវរងា-រដូវក្ដៅ៖**
ការជ្រើសរើសបុគ្គលិកថ្មី និង ការណែនាំអំពីទំនួលខុសត្រូវ

**02**

### ការចូលរួមពីភាគីពាក់ព័ន្ធ

**និទាឃរដូវ -រដូវក្ដៅ៖**
ខាងក្នុង និងខាងក្រៅ កំណត់គោលដៅឱ្យបានទូលំទូលាយជាងមុន

**03**

### សេចក្តីព្រាងបទប្បញ្ញត្តិ

**ចុងរដូវក្ដៅ/រដូវស្លឹកឈើជ្រុះ៖**
បោះពុម្ពផ្សាយសេចក្តីព្រាងបទប្បញ្ញត្តិ
*(បទប្បញ្ញត្តិចុងក្រោយដល់កាលកំណត់ត្រឹមថ្ងៃទី 1 ខែ មីនា ឆ្នាំ 2026)*

# ទាក់ទងមកយើងខ្ញុំ

100 Cambridge St. - 9th Floor - Boston, MA 02114

doer.siting.permitting@mass.gov

(617) 626-7300

x.com/massdoer

bsky.app/profile/massdoer.bsky.social

www.mass.gov/orgs/massachusetts-department-of-energy-resources

## យើងទន្ទឹងរង់ចាំទទួលបានព័ត៌មានពីអ្នក។



# លក្ខខណ្ឌតម្រូវនៃការចូលរួមក្នុងការដាក់ឯកសារជាមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)

ពង្រាងសំណើរបស់បុគ្គលិកនាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) និង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)

ថ្ងៃទី 24 ខែមេសា ឆ្នាំ 2025

## លក្ខខណ្ឌតម្រូវនៃការដាក់ឯកសារជាមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)

- តម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) កំណត់លក្ខខណ្ឌតម្រូវមុនពេលដាក់ឯកសារ។ ច្បាប់ទូទៅនៃជំពូកទី 164, §69T
  - អំពាវនាវឱ្យមានការពិគ្រោះយោបល់ជាមុនជាមួយទីភ្នាក់ងារផ្តល់អនុញ្ញាត និងការិយាល័យច្បាប់ស្តីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA) ។
  - តម្រូវឱ្យមានកិច្ចប្រជុំសាធារណៈ និងទម្រង់នៃការផ្សព្វផ្សាយផ្សេងទៀត មុនពេលអ្នកដាក់ពាក្យស្នើសុំដាក់បញ្ជូនសំណើទៅកាន់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)។
- តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ភស្តុតាងដែលថាការពិគ្រោះយោបល់មុនពេលដាក់ឯកសារមុនពេលដាក់ឯកសារ និងលក្ខខណ្ឌតម្រូវឱ្យមានការចូលរួមរបស់សហគមន៍ទាំងអស់ត្រូវបានបំពេញតាម។

## តួនាទីរបស់ផ្នែកនៃការចូលរួមជាសាធារណៈ

- បង្កើតផ្នែកនៃការចូលរួមជាសាធារណៈ (DPP) នៅនាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) ដើម្បី៖
  - ជួយដល់ភាគីពាក់ព័ន្ធក្នុងការធ្វើដំណើរ និងបញ្ជាក់តម្រូវការមុនការដាក់បញ្ចូលក្នុងការសម្របសម្រួលជាមួយនឹងការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន (OEJE) របស់កិច្ចការថាមពល និងបរិស្ថាន (EEA) និង
  - សម្របសម្រួលការសន្ទនារវាងភាគីពាក់ព័ន្ធដែលពាក់ព័ន្ធនឹងដំណើរការនៃការអនុញ្ញាត។

# ការអនុវត្តនៃការដាក់ឯកសារជាមុនដែលមានស្រាប់របស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង

បច្ចុប្បន្នក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) មិនមានលក្ខខណ្ឌតម្រូវនៃការចូលរួមដោយដាក់ឯកសារជាមុនដោយលម្អិតឡើយ

ការផ្សព្វផ្សាយជាមុនបានប្រែប្រួលនៅទូទាំងគម្រោង

ការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនដោយអ្នកគាំទ្រគម្រោងរួមមាន៖

- ការផ្សព្វផ្សាយដោយការចុះទៅតាមលំនៅឋានទៅលំនៅឋានមួយទៀតទៅដល់ម្ចាស់កម្មសិទ្ធិគម្រោងការប្រជុំសាធារណៈក្រៅផ្លូវការ និងការពិគ្រោះយោបល់របស់អាជ្ញាធរក្រុង
- អ៊ីមែល និងព័ត៌មាននៅលើគេហទំព័រគម្រោង

អ្នកគាំទ្របានផ្តល់ព័ត៌មានរួមទាំងតម្រូវការគម្រោង ការពិចារណាលើការរចនា និងកាលវិភាគសម្រាប់គម្រោង

គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលតាមរយៈការពិនិត្យឡើងវិញ (ច្បាប់ស្តីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA)) ត្រូវតែអនុលោមតាមតម្រូវការមុនពេលដាក់ឯកសារសម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន

# វត្ថុបំណងសម្រាប់លក្ខខណ្ឌតម្រូវនៃការចូលរួមក្នុងការដាក់ឯកសារជាមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)

បង្កើតលក្ខខណ្ឌតម្រូវនៃការដាក់ឯកសារជាមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) ពន្លឿន ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នានៃការអនុវត្តការផ្សព្វផ្សាយនៅទូទាំងគម្រោង

សូមប្រាកដថាព័ត៌មានគម្រោងបានទៅដល់បុគ្គលឬអង្គភាពដែលអាចរងផលប៉ះពាល់ដោយគម្រោងនៅដើមដំបូងនៃដំណើរការអភិវឌ្ឍគម្រោង

ផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធសំខាន់ៗដើម្បីឱ្យមានឥទ្ធិពលលើការរចនាគម្រោងក្នុងដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍគម្រោង

លើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជនកាន់តែទូលំទូលាយ

# បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត

| ប្រភេទ/ការពិពណ៌នាអំពីបរិក្ខារ | សមត្ថភាព/ទំហំ | សិទ្ធអំណាចនៃការអនុញ្ញាត |
|---|---|---|
| **<u>ការបង្កើតថាមពល</u>** – ពន្លឺព្រះអាទិត្យ ទួរប៊ីនខ្យល់ ដំណើរការរំលាយជាតិសរីរាង្គដោយគ្មានអុកស៊ីសែន | ≥ 25 MW (**ទ្រង់ទ្រាយធំ**) | ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាម § 69T |
| | < 25 MW (**ទ្រង់ទ្រាយតូច**) | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមជំពូក 25A, § 21 [1]<br>ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) – ការអនុញ្ញាតជារួមរបស់រដ្ឋស្របតាមច្បាប់ § 69V ( ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) ដែលអ្នកអភិវឌ្ឍជ្រើសចូលរួម) បើមិនដូច្នេះទេ ត្រូវមានការអនុញ្ញាតរបស់រដ្ឋនីមួយៗ |
| **<u>ប្រព័ន្ធផ្ទុកថាមពល</u>** | ≥100 MWh (**ទ្រង់ទ្រាយធំ**) | ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) – ការអនុញ្ញាតជារួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមច្បាប់ § 69T |
| | < 100 MWh (**ទ្រង់ទ្រាយតូច**) | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមជំពូក 25A, § 21 [1]<br>ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) – ការអនុញ្ញាតរួមរបស់រដ្ឋស្របតាមច្បាប់ § 69V ( ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) ដែលអ្នកបង្កើតជ្រើសរើសចូលរួម) មិនដូច្នោះទេ ត្រូវមានការអនុញ្ញាតរបស់រដ្ឋនីមួយៗផ្សេងពីគ្នា |
| **<u>ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល</u>** (និងបរិក្ខារជំនួយ) - **ទ្រង់ទ្រាយធំ**<br>- ≥69 kV <u>និង</u> ≥ 1 ម៉ាយល៍ (ច្រករបៀងថ្មី)<br>- ≥115 kV <u>និង</u> ≥10 ម៉ាយល៍ (ច្រករបៀងដែលមានស្រាប់) (លើកលែងតែការបញ្ជូនឡើងវិញក្នុងតង់ស្យុងដូចគ្នា)<br>- ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពលថ្មី (រួមទាំងស្ថានីយរង/រចនាសម្ព័ន្ធ) ដែលតម្រូវឱ្យមានការលើកលែងពីការកំណត់តំបន់<br>- បរិក្ខាដែលត្រូវការដើម្បីភ្ជាប់នឹងទួរប៊ីនខ្យល់នៅឯនាយសមុទ្រទៅបណ្តាញចែកចាយអគ្គិសនី | | ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាម § 69T<br><br>ការលើកលែងពីការកំណត់តំបន់របស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) <u>ក៏</u>ត្រូវបានទាមទារផងដែរ |
| **<u>ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល</u>** (និងបរិក្ខារជំនួយ) - **ទ្រង់ទ្រាយតូច**<br>- <1 ម៉ាយល៍ (ច្រករបៀងថ្មី)<br>- <10 ម៉ាយល៍ (ច្រករបៀងដែលមានស្រាប់)<br>- គម្រោងកម្រិតចែកចាយដែលបំពេញតាមដែនកម្រិតកំណត់នៃទំហំដែលនឹងត្រូវកំណត់ពេលក្រោយដោយក្រសួងធនធានថាមពល (DOER)<br>- ការបញ្ជូនថាមពលបន្ត/ការសាងសង់ឡើងវិញក្នុងកម្រិតតង់ស្យុងដូចគ្នា<br>- ស្ថានីយរង/ការដំឡើងកម្រិតដែល<u>មិន</u>តម្រូវឱ្យមានការលើកលែងការកំណត់តំបន់ | | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមជំពូកទី 25A, § 21<br><br>**- ឬ -**<br><br>ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមច្បាប់ § 69U ( ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) ដែលអ្នកអភិវឌ្ឍជ្រើសរើសចូលរួម) |

1. ដំណើរការដាក់ឯកសារជាមុននឹងធ្វើឡើងជាលើកដំបូងក្រោមគោលការណ៍ណែនាំអំពីការអនុញ្ញាតរួមក្នុងមូលដ្ឋានរបស់ក្រសួងធនធានថាមពល (DOER) ហើយនឹងមិនត្រូវស្ថិតក្រោមដំណើរការដាក់ឯកសារជាមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) នោះទេ។ រដ្ឋាភិបាលក្នុងមូលដ្ឋានអាចផ្ទេរពាក្យសុំការអនុញ្ញាតរួមក្នុងតំបន់ទៅនាយករបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) ប្រសិនបើធនធាន និងចំនួនបុគ្គលិកមិនអនុញ្ញាតឱ្យមានការត្រួតពិនិត្យក្នុងមូលដ្ឋានស្របតាមច្បាប់ § 69W ទេនោះ។ សំណើសុំសម្រាប់ការវិនិច្ឆ័យពីសេចក្តីសម្រេចអំពីការអនុញ្ញាតរួមក្នុងមូលដ្ឋានជាថ្មីក៏អាចត្រូវបានដាក់ជូនទៅនាយកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) ស្របតាមច្បាប់ § 69W ហើយនឹងមិនតម្រូវឱ្យមានដំណើរការដាក់ឯកសារជាមុនបន្ថែមឡើយ។

ពណ៌គន្លឹះ៖ ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងផលិតថាមពល (EFSB) ទំនួលខុសត្រូវរបស់ក្រសួងធនធានថាមពល (DOER) ដើម្បីបង្កើតស្តង់ដា

# លក្ខខណ្ឌតម្រូវនៃផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង

- លក្ខខណ្ឌតម្រូវនៃការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុន
  - លក្ខខណ្ឌតម្រូវនៃការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនដំណាក់កាលទី 1
  - លក្ខខណ្ឌតម្រូវនៃការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនដំណាក់កាលទី 2
- សេចក្តីជូនដំណឹងអំពីចេតនាក្នុងការដាក់ពាក្យសុំឯកសារជាមុន
- ឯកសារដែលត្រូវដាក់ស្នើ (ដាក់ស្នើ) រួមជាមួយនឹងការជូនដំណឹងអំពីការដាក់ឯកសារជាមុន

## លក្ខខណ្ឌតម្រូវនៃការផ្សព្វផ្សាយអំពីការការដាក់ឯកសារជាមុនតាមដំណាក់កាល

### ដំណាក់កាលទី 1 ការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុន

- កើតឡើងក្នុងអំឡុងពេលធ្វើផែនការគម្រោងនៅពេលដែលផ្លូវ និង/ឬទីតាំងដែលមាន សក្តានុពលជាច្រើនកំពុងត្រូវបានពិចារណា។
- ស្វែងរកមតិកែលម្អដែលមានការគោលដៅពីភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងទីភ្នាក់ងារអនុញ្ញាតរបស់រដ្ឋ និងមូលដ្ឋាន ម្ចាស់កម្មសិទ្ធិគម្រោង ក្រុមសហគមន៍និងអ្នកតំណាងក្រុង

### ដំណាក់កាលទី 2 ការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុន

- កើតឡើងនៅពេលដែលមានសំណុំនៃផ្លូវ និង/ឬទីតាំងដែលមាន សក្តានុពលដែលឆ្លើយតបទៅនឹងការបញ្ចូលពីការផ្សព្វផ្សាយដំណាក់កាលទី 1។
- រួមបញ្ចូលការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធដំណាក់កាលទី 1 និងសហគមន៍កាន់តែទូលំទូលាយដើម្បីប្រមូលមតិកែលម្អ ហើយតម្រូវឱ្យ អ្នកដាក់ពាក្យស្នើសុំធ្វើការប្រជុំសាធារណៈយ៉ាងហោចណាស់ពីរដង។

**រយៈពេលនៃការចូលរួមក្នុងការដាក់ឯកសារជាមុន**

បរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលស្អាតទ្រង់ទ្រាយធំ – យ៉ាងហោចណាស់ រយៈពេល 15 ខែ

បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយតូច – យ៉ាងហោចណាស់រយៈពេល 12 ខែ

# ការកំណត់ពេលវេលា និងរយៈពេលនៃតម្រូវការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនដំណាក់កាលទី 1

| លក្ខខណ្ឌតម្រូវឱ្យមានការផ្សព្វផ្សាយក្នុងការដាក់ឯកសារជាមុនសម្រាប់អ្នកគាំទ្រ | បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយធំ | | បរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលស្អាតទ្រង់ទ្រាយតូច | |
|---|---|---|---|---|
| | ការកំណត់ពេលវេលា | រយៈពេល | ការកំណត់ពេលវេលា | រយៈពេល |
| ជួបជាមួយផ្នែកនៃការចូលរួមជាសាធារណៈ (DPP) និងការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន (OEJE) ដើម្បីបញ្ជាក់ពីការផ្សព្វផ្សាយ និងបញ្ជាក់ពីតម្រូវការឯកសារ | យ៉ាងហោចណាស់រយៈពេល 12 ខែមុនពេលជូនដំណឹងអំពីការដាក់ឯកសារជាមុនទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) | គ្មាន | យ៉ាងហោចណាស់រយៈពេល 9 ខែ មុនពេលជូនដំណឹងអំពីការដាក់ឯកសារជាមុនទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) | គ្មាន |
| ពិគ្រោះជាមួយទីភ្នាក់ងារអនុញ្ញាតក្នុងមូលដ្ឋានរបស់ច្បាប់ស្តីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA) និងរដ្ឋតាមភាពសមស្រប | ចាប់ផ្តើមយ៉ាងហោចណាស់រយៈពេល 12 ខែមុនពេលជូនដំណឹងអំពីការដាក់ឯកសារជាមុនទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) | យ៉ាងហោចណាស់រយៈពេល 3 ខែ | មិនតម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយច្បាប់ស្តីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA) ទេ | យ៉ាងហោចណាស់រយៈពេល 3 ខែ |
| ពិចារណាលើលក្ខណៈវិនិច្ឆ័យសមស្របរបស់ទីតាំង និងការណែនាំអំពីការវិភាគផលប៉ះពាល់រួម | | | ចាប់ផ្តើមយ៉ាងហោចណាស់រយៈពេល 9 ខែមុនពេលជូនដំណឹងអំពីការដាក់ឯកសារជាមុនទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) | |
| ជួបជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងមន្ត្រីទីក្រុង ម្ចាស់កម្មសិទ្ធិគម្រោងដែលមានសក្តានុពល និងក្រុមសហគមន៍ | | | | |
| ដាក់បញ្ជូនបញ្ជីត្រួតពិនិត្យនៃការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 1 ដោយខ្លួនឯងទៅផ្នែកនៃការចូលរួមជាសាធារណៈ (DPP) និងធ្វើបច្ចុប្បន្នភាពគេហទំព័រគម្រោងជាមួយព័ត៌មានការផ្សព្វផ្សាយដំណាក់កាលទី 1 | តំណាងឱ្យចុងបញ្ចប់នៃការផ្សព្វផ្សាយដំណាក់កាលទី 1 | | តំណាងឱ្យចុងបញ្ចប់នៃការផ្សព្វផ្សាយដំណាក់កាលទី 1 | |

| លក្ខខណ្ឌតម្រូវឱ្យមានការផ្សព្វផ្សាយក្នុងការដាក់ឯកសារជាមុនសម្រាប់អ្នកគាំទ្រ | បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយធំ | | បរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលស្អាតទ្រង់ទ្រាយតូច | |
|---|---|---|---|---|
| | ការកំណត់ពេលវេលា | រយៈពេល | ការកំណត់ពេលវេលា | រយៈពេល |
| បង្ហាញកិច្ចខិតខំប្រឹងប្រែងដើម្បីជូនដំណឹង ការចូលរួម និងភាពជាដៃគូជាមួយអង្គការក្នុងសហគមន៍ មន្ត្រីរបស់រដ្ឋ និងទីក្រុង | ការផ្សព្វផ្សាយពេញមួយដំណាក់កាលទី 2 | រយៈពេល 9 ខែ | ការផ្សព្វផ្សាយពេញមួយដំណាក់កាលទី 2 | រយៈពេល 6 ខែ |
| ផ្សព្វផ្សាយព័ត៌មានអំពីគម្រោងជាសាធារណៈ និងបន្តធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់គម្រោង | | | | |
| រៀបចំកិច្ចប្រជុំសាធារណៈលើកដំបូង | ហៀបនឹងចាប់ផ្តើមដំណាក់កាលទី 2 | | ហៀបនឹងចាប់ផ្តើមដំណាក់កាលទី 2 | |
| ធ្វើការពិគ្រោះយោបល់ (លើកទីពីរ) ជាមួយច្បាប់ស្តីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA) និងទីភ្នាក់ងារផ្តល់ការអនុញ្ញាតក្នុងរដ្ឋ និងក្នុងមូលដ្ឋាន | បន្ទាប់ពីកិច្ចប្រជុំសាធារណៈលើកដំបូង | | បន្ទាប់ពីកិច្ចប្រជុំសាធារណៈលើកដំបូង | |
| ការដាក់ស្នើសេចក្តីជូនដំណឹងអំពីការដាក់ឯកសារជាមុនទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) | មិនតិចជាងរយៈពេល 90 ថ្ងៃ និងមិនលើសពីរយៈពេល 120 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំគម្រោង | រយៈពេល 3 ខែ | មិនតិចជាងរយៈពេល 90 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំគម្រោង | រយៈពេល 3 ខែ |
| រៀបចំកិច្ចប្រជុំសាធារណៈលើកទីពីរ | យ៉ាងហោចណាស់រយៈពេល 45 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំគម្រោងជាមួយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) | | យ៉ាងហោចណាស់រយៈពេល 45 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំគម្រោងជាមួយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) | |
| ដាក់បញ្ជូនបញ្ជីផ្ទៀងផ្ទាត់ការបញ្ចប់នៃការផ្សព្វផ្សាយដំណាក់កាលទី 2 ដោយខ្លួនឯងទៅកាន់ផ្នែកនៃការចូលរួមជាសាធារណៈ (DPP) | តំណាងឱ្យចុងបញ្ចប់នៃការផ្សព្វផ្សាយដំណាក់កាលទី 2 | | តំណាងឱ្យចុងបញ្ចប់នៃការផ្សព្វផ្សាយដំណាក់កាលទី 2 | |

# ការកំណត់ពេលវេលា និងរយៈពេលនៃតម្រូវការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនដំណាក់កាលទី 2

# ព័ត៌មានដែលបានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងពេលផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនដំណាក់កាលទី 1

ការពិពណ៌នាអំពីគម្រោង

គោលបំណង និងតម្រូវការរបស់គម្រោង

រាល់ផ្លូវ / តំបន់ដែលមានសក្តានុពលទាំងអស់ដែលកំពុងត្រូវបានពិចារណាជាមួយនឹងផែនទីទីតាំង

ការប្រៀបធៀបទូទៅអំពីផលប៉ះពាល់ដែលរំពឹងទុកនៃជម្រើសនីមួយៗក្រោមការពិចារណា

របៀបដែលផ្លូវ/តំបន់ដែលកំពុងត្រូវបានពិចារណាដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្របរបស់ទីតាំង និងការណែនាំអំពីការវិភាគផលប៉ះពាល់រួម (CIA)

បញ្ជីនៃការអនុញ្ញាតរបស់សហព័ន្ធ តំបន់ រដ្ឋ និងមូលដ្ឋានដែលត្រូវការ

ពេលវេលាដែលបានប៉ាន់ស្មានសម្រាប់ការដាក់ពាក្យស្នើសុំជាមួយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB)

ឱកាសនាពេលអនាគតសម្រាប់ការផ្តល់មតិយោបល់លើគម្រោង

---

✓ នៅចុងបញ្ចប់នៃការផ្សព្វផ្សាយដំណាក់កាលទី 1 អ្នកគាំទ្រគួរតែបង្ហោះព័ត៌មានខាងក្រោមនៅលើគេហទំព័រគម្រោង - ឯកសារដែលបានចែករំលែកក្នុងអំឡុងពេលកិច្ចប្រជុំដំណាក់កាលទី 1 បញ្ជីភាគីពាក់ព័ន្ធដែលបានទាក់ទងមតិកែលម្អដែលទទួលបាន និងរបៀបដែលមតិកែលម្អនោះត្រូវបានពិចារណា រួមទាំងការផ្លាស់ប្តូរ ឬការដកផ្លូវ/តំបន់ចេញដែលកំពុងត្រូវបានពិចារណា

## ដំណាក់កាលទី 1 – ការផ្សព្វផ្សាយដែលមានគោលដៅដល់ភាគីពាក់ព័ន្ធសំខាន់ៗ

# ព័ត៌មានដែលបានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងពេលនៃការផ្សព្វផ្សាយអំពីការដាក់ឯកសារជាមុនដំណាក់កាលទី 2

របៀបដែលអ្នកដាក់ពាក្យស្នើសុំគម្រោងបានឆ្លើយតបទៅនឹងមតិកែលម្អដំណាក់កាលទី 1 រួមទាំងលក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើសម្រាប់ការដកសផ្លូវ/ទីតាំងដាក់លាក់ ឬជម្រើសចំណាត់ថ្នាក់ ចេញ

របៀបដែលផ្លូវ/តំបន់នានាដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្របរបស់ទីតាំង និងការណែនាំអំពីការវិភាគផលប៉ះពាល់រួម ផលប៉ះពាល់បរិស្ថាន សុខភាព និងសុវត្ថិភាពដែលអាចកើតមាន

លទ្ធផលនៃការសិក្សា ឬការវិភាគណាមួយដែលកំពុងដំណើរការ ឬបានបញ្ចប់

គេហទំព័ររបស់គម្រោងគួរតែរួមបញ្ចូលព័ត៌មានរបស់គម្រោងបច្ចុប្បន្ន សេចក្តីសង្ខេបភាសាបែបសាមញ្ញ ព័ត៌មានបច្ចុប្បន្នលើជម្រើសផ្លូវ/តំបន់ដែលស្ថិតក្រោមការពិចារណា ឯកសារផ្សព្វផ្សាយព័ត៌មានទំនាក់ទំនងរបស់អ្នកគាំទ្រគម្រោង របៀបស្នើសុំការបកប្រែ និង/ឬការបកប្រែផ្ទាល់មាត់ ជម្រើសក្នុងការចុះឈ្មោះក្នុងបញ្ជីចែកចាយអ៊ីមែលរបស់គម្រោង

អ្នកដែលបានចុះហត្ថលេខាលើបញ្ជីចែកចាយអ៊ីមែលគួរតែទទួលបានវឌ្ឍនភាពគម្រោងដែលមានបច្ចុប្បន្នភាពប្រចាំត្រីមាស ការរំលឹកអំពីរបៀបដាក់បញ្ចូនមតិយោបល់/ការចូលរួម និងពេលវេលាប៉ាន់ស្មានសម្រាប់ការដាក់ពាក្យស្នើសុំជាមួយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB)

✓ នៅចុងបញ្ចប់នៃអ្នកគាំទ្រការផ្សព្វផ្សាយដំណាក់កាលទី 2 គួរតែដាក់បញ្ចូនបញ្ជីត្រួតពិនិត្យបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 2 ដោយខ្លួនឯងទៅផ្នែកនៃការចូលរួមជាសាធារណៈ (DPP) មុនពេលដាក់ពាក្យស្នើសុំគម្រោងជាមួយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB)

ដំណាក់កាលទី 2 – ការផ្សព្វផ្សាយសហគមន៍កាន់តែទូលំទូលាយ + ការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធដំណាក់កាលទី 1

# លក្ខខណ្ឌតម្រូវនៃការចូលរួមក្នុងការដាក់ឯកសារជាមុនសម្រាប់អ្នកគាំទ្រគម្រោង

- រៀបចំសម្រាប់ការបកប្រែផ្ទាល់មាត់ និង/ឬឯកសារដែលមានការបកប្រែតាមការស្នើសុំសម្រាប់ដំណាក់កាលទី 1 និងស្របតាមការអនុវត្តរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) សម្រាប់ការកំណត់តំបន់ភូមិសាស្ត្រដែលកំណត់ដោយជំនាញភាសាអង់គ្លេសមានកម្រិត ដូចមានចែងក្នុងផែនការចូលប្រើភាសារបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB)(ផែនការចូលប្រើភាសា (LAP)) ក្នុងដំណាក់កាលទី 2។ ឯកសារផ្សព្វផ្សាយក៏គួរតែរួមបញ្ចូលព័ត៌មានអំពីរបៀបស្នើសុំសេវាបកប្រែ និង/ឬសេវាបកប្រែផ្ទាល់មាត់បានផងដែរ។

- សម្របសម្រួលការផ្សព្វផ្សាយដោយផ្អែកលើផលប៉ះពាល់ និងអត្ថប្រយោជន៍របស់គម្រោង និងប្រជាសាស្ត្រនៃប្រជាជនដែលរងផលប៉ះពាល់អាចកើតមាន

- **រៀបចំការប្រជុំសាធារណៈនៅពេលសមហេតុផល និងនៅទីតាំងដែលសមាជិកសហគមន៍ប្រើប្រាស់ជាប្រចាំ**

- **ប្រើបណ្តាញផ្សព្វផ្សាយជាច្រើនរួមមានការផ្សព្វផ្សាដោយចុះទៅតាមផ្ទះ អ៊ីមែល ប្រព័ន្ធផ្សព្វផ្សាយសង្គម ខិត្តប័ណ្ណនៅក្នុងកន្លែងប្រមូលផ្តុំរបស់សហគមន៍ ប៉ុស្តិ៍វិទ្យុ**

- រួមបញ្ចូលពេលវេលាគ្រប់គ្រាន់សម្រាប់ការទទួលមតិយោបល់ជាសាធារណៈ និងឆ្លើយសំណួររបស់ភាគីពាក់ព័ន្ធក្នុងអំឡុងពេលកិច្ចប្រជុំសាធារណៈ។ ការរៀបចំកិច្ចប្រជុំចម្រុះត្រូវបានលើកទឹកចិត្តដើម្បីធ្វើឱ្យវាអាចចូលប្រើបានសម្រាប់មនុស្សកាន់តែច្រើន

# ការចងក្រងឯកសារដែលត្រូវបានដាក់ជូនជាមួយនឹងការជូនដំណឹងអំពីការដាក់ឯកសារជាមុន

- ✓បញ្ជាក់ពេលវេលានៃការប្រជុំជាមួយបុគ្គលិកផ្នែកនៃការចូលរួមជាសាធារណៈ (DPP) និងការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន (OEJE)
- ✓ការបញ្ជាក់ដោយខ្លួនឯងថារាល់តម្រូវការនៃការផ្សព្វផ្សាយដំណាក់កាលទី 1ត្រូវបានបំពេញតាម និងស្ថិតិនៃកិច្ចខិតខំប្រឹងប្រែងលើការផ្សព្វផ្សាយដំណាក់កាលទី 2
- ✓ព័ត៌មានអំពីឯកសារសម្រាប់ការផ្សព្វផ្សាយដែលបានបង្កើត អ្នកទទួលបានការផ្សព្វផ្សាយកាលបរិច្ឆេទទំនាក់ទំនង និងឧបករណ៍ដែលត្រូវបានប្រើដើម្បីចូលរួម និងលើកទឹកចិត្តការចូលរួមពីភាគីពាក់ព័ន្ធ
- ✓ទីភ្នាក់ងារសម្រាប់ការប្រជុំសហគមន៍ដែលបានធ្វើឡើង កំណត់ចំណាំនៃកិច្ចប្រជុំដែលមានរួមបញ្ចូលការព្រួយបារម្ភ សំណូមពរ និងជម្រើស/ការកែប្រែទីតាំងណាមួយ
- ✓សេចក្តីសង្ខេបឧបសម្ព័ន្ធដែលបានទទួលមតិយោបល់មុនពេលដាក់ឯកសារពីរបៀបដែលវាត្រូវបានពិចារណាក្នុងការរចនាគម្រោង និងការកែប្រែការរចនាដ៏សំខាន់ណាមួយ
- ✓ភាពជាដៃគូណាមួយដែលបានបង្កើតឡើងជាមួយភាគីពាក់ព័ន្ធក្នុងតំបន់ដើម្បីផ្តល់មតិយោបល់ជាស្ថាប័នប្រឹក្សាយោបល់
- ✓ផែនការអត្ថប្រយោជន៍នៅក្នុងសហគមន៍ត្រូវបានបង្កើតឡើង ប្រសិនបើមាន

# សំណើសុំមតិយោបល់

- តើមានជម្រើសទីតាំង/ផ្លូវចំនួនប៉ុន្មានដែលជាធម្មតាត្រូវបានពិចារណាសម្រាប់ប្រភេទគម្រោងផ្សេងៗគ្នា (ឧទាហរណ៍ ថាមពលពន្លឺព្រះអាទិត្យ ទួប៊ីនខ្យល់ កន្លែងផ្ទុកអាគុយ ការបញ្ជូនថាមពល)? តើដំណាក់កាលនៃវដ្តនៃការអភិវឌ្ឍគម្រោងអ្វីខ្លះ ដែលជាជម្រើសនៃទីតាំង/ផ្លូវរបស់គម្រោងដែលកំពុងត្រូវបានពិចារណាដោយត្រៀមរួចរាល់ដើម្បីចែករំលែកជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងពេលផ្សព្វផ្សាយដំណាក់កាលទី 1?
- តើនៅពេលណាដែលការដាក់ពាក្យសុំចូលរួមជាមុនគួរតែផ្លាស់ប្តូរពីដំណាក់កាលទី 1 (ការផ្សព្វផ្សាយគោលដៅទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗ) ទៅដំណាក់កាលទី 2 (ការចែករំលែកព័ត៌មានកាន់តែទូលំទូលាយជាមួយសហគមន៍កាន់តែទូលំទូលាយ)? តើវាគួរតែផ្អែកលើចំនួនផ្លូវ/ទីតាំងដែលត្រូវបានគេពិចារណា ឬវិភាគផ្សេងទៀតដែរឬទេ?
- ពង្រាងសំណើបានស្នើថាតម្រូវការផ្សព្វផ្សាយដំណាក់កាលទី 2 សម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយធំ គួរតែចាប់ផ្តើមយ៉ាងហោចណាស់រយៈពេល 9 ខែមុនពេលអ្នកគាំទ្រដាក់ស្នើសេចក្តីជូនដំណឹងជាមុនទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB)។ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយតូច ដែលនឹងទទួលបានការពិនិត្យឡើងវិញពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល (EFSB) ដំណាក់កាលទី 2 គួរតែចាប់ផ្តើមយ៉ាងហោចណាស់រយៈពេល 6 ខែមុន។ តើការកំណត់ពេលវេលាបែបនេះត្រូវបានផ្លាស់ប្តូរដែរឬទេ? ប្រសិនបើត្រូវការ តើអ្វីជាកាលវិភាគដែលបានស្នើឡើង?
- តើមានតម្រូវការបន្ថែមមុនពេលដាក់ឯកសារដែលគួរតែត្រូវបានពិចារណាដើម្បីបង្កើនតម្លាភាព និងធានាថាភាគីពាក់ព័ន្ធដែលមានផលប៉ះពាល់មានឱកាសផ្តល់មតិយោបល់ ជាពិសេសជុំវិញការជ្រើសរើសផ្លូវ/ទីតាំងដែរឬទេ?

# កម្មវិធីជំនួយឧបត្ថម្ភអន្តរការីរបស់នាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) និង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB)

ពង្រាងសំណើរបស់បុគ្គលិក

ថ្ងៃទី 24 ខែមេសា ឆ្នាំ 2025

# បទប្បញ្ញត្តិនៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 សម្រាប់កម្មវិធីជំនួយគាំទ្រអន្តរាគមន៍របស់ DPU និង EFSB

- បង្កើតមូលនិធិជំនួយគាំទ្រអន្តរការី (G.L. c. 25, §12S)
- តម្រូវឱ្យនាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) និងក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) ក្នុងការពិគ្រោះយោបល់ជាមួយការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន (OEJE) និងការិយាល័យមេធាវីក្នុងការប្រកាសបទប្បញ្ញត្តិដើម្បីអនុវត្តកម្មវិធីជំនួយគាំទ្រអន្តរការីត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2026 (ច្បាប់ទូទៅនៃជំពូកទី 164, § 149)
- បង្កើត ផ្នែកនៃនាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) របស់ផ្នែកនៃការចូលរួមជាសាធារណៈ (DPP) (ច្បាប់ទូទៅនៃជំពូកទី 25, §12T)
  - ការផ្តល់កាតព្វកិច្ចដល់ DPP ជាមួយនឹងការណែនាំដើម្បីកំណត់ឱកាសក្នុងការធ្វើអន្តរាគមន៍សម្របសម្រួលការសន្ទនារវាងភាគីក្នុងដំណើរការនីតិវិធី
- អនុញ្ញាតឱ្យនាយកនៃ DPP ធ្វើការកំណត់លើសំណើផ្តល់មូលនិធិ និង គ្រប់គ្រងគ្រប់ទិដ្ឋភាពទាំងអស់នៃកម្មវិធីជំនួយគាំទ្រអន្តរការី (G.L. c. 164, § 149)

## គោលដៅនៃកម្មវិធីជំនួយគាំទ្រអន្តរការី

- ផ្តល់ជំនួយហិរញ្ញវត្ថុដល់អង្គភាពដែលមានសិទ្ធិទទួលបាន (ឧទាហរណ៍ ក្រុមសហគមន៍ អាជ្ញាធរក្រុងតូចៗ) ដែលមិនអាចចូលរួមក្នុងដំណើរការនីតិវិធីនៅចំពោះមុខនាយកដ្ឋានសេវាសាធារណៈប្រើប្រាស់ក្នុងផ្ទះ (DPU) និងក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) បាន ដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ
- អនុញ្ញាតឱ្យម្ចាស់ជំនួយរ៉ាប់រងលើថ្លៃសេវាមេធាវី សាក្សីជំនាញ អ្នកជំនាញសហគមន៍ រដ្ឋបាល និងការចំណាយដែលមានសិទ្ធិផ្សេងទៀត
- ផ្តល់សំឡេងនិងទស្សនៈចម្រុះក្នុងការសម្រេចចិត្តទាក់ទងនឹងថាមពល

# យន្តការផ្តល់មូលនិធិ និងអាជ្ញាធរវាយតម្លៃ

- ✓ G.L. c. 25, §12S ផ្តល់សិទ្ធិដល់ DPU ក្នុងការផ្តល់ឥណទានដូចខាងក្រោមទៅមូលនិធិ៖
  - ការផ្តល់សេវាកម្មដែលត្រូវបានកំណត់ជាពិសេសដើម្បីផ្ទេរទៅកាន់មូលនិធិ
  - ផ្នែកមួយនៃការវាយតម្លៃប្រចាំឆ្នាំដែលប្រមូលបានពីក្រុមហ៊ុនអគ្គិសនី និងឧស្ម័នក្រោមយុត្តាធិការរបស់ DPU
  - ផ្នែកនៃថ្លៃដាក់ពាក្យសុំដើម្បីសាងសង់កន្លែងEFSB-យុត្តាធិការ
  - ប្រភពដែលផ្តល់មូលនិធិដោយអ្នកមិនជាប់ពន្ធ ឬប្រាក់ចំណូលដែលទទួលបានពីការវិនិយោគនៃចំនួនទឹកប្រាក់ដែលបានផ្តល់ឥណទានដល់មូលនិធិ**និង**
  - សមតុល្យដែលមិនបានប្រើណាមួយត្រូវទុកនៅក្នុងមូលនិធិសម្រាប់ការប្រើប្រាស់ក្នុងឆ្នាំសារពើពន្ធបន្ទាប់។

- ✓ G.L. c. 25, §18អនុញ្ញាតឱ្យគណៈកម្មការ DPU ធ្វើការវាយតម្លៃដូចខាងក្រោម៖
  - វាយតម្លៃ 0.1% នៃប្រាក់ចំណូលប្រតិបត្តិការផ្ទៃក្នុងរបស់ក្រុមហ៊ុនអគ្គិសនីក្រោមយុត្តាធិការរបស់ DPU។ ផ្នែកមួយនៃការវាយតម្លៃនេះនឹងត្រូវបានផ្តល់ឥណទានដល់មូលនិធិ
  - វាយតម្លៃប្រាក់ចំណូលប្រតិបត្តិការផ្ទៃក្នុងរបស់ក្រុមហ៊ុនឧស្ម័ន និងអគ្គិសនីក្រោមយុត្តាធិការរបស់ DPU ដើម្បីផលិតចំនួនទឹកប្រាក់មិនលើសពី 3.5 លានដុល្លារក្នុងមួយឆ្នាំ ដើម្បីគាំទ្រដល់កម្មវិធី
  - ផ្នែកមួយនៃការវាយតម្លៃត្រូវបញ្ចូលទៅក្នុងមូលនិធិ EFSB Trust Fund និងមូលនិធិគាំទ្រអន្តរាគមន៍របស់ DPU និង EFSB ហើយនិង
  - មូលនិធិដែលមិនបានចំណាយនឹងត្រូវបានផ្តល់ឥណទានប្រឆាំងនឹងការវាយតម្លៃដែលបានធ្វើឡើងនៅឆ្នាំបន្ទាប់ ហើយការវាយតម្លៃនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់នឹងត្រូវបានកាត់បន្ថយដោយចំនួនដែលមិនបានចំណាយ។

# ភាគីដែលមានសិទ្ធិទទួលបានមូលនិធិជំនួយគាំទ្រអន្តរាគមន៍

- ✓ អង្គការ និងអង្គភាពដែលតស៊ូមតិក្នុងនាមអតិថិជនលំនៅឋាន ត្រូវបានកំណត់តាមភូមិសាស្ត្រ ឬផ្អែកលើផលប្រយោជន៍រួមជាក់លាក់
- ✓ អង្គការ និងអង្គភាពដែលតស៊ូមតិក្នុងនាមប្រជាជនលំនៅឋានដែលមានប្រាក់ចំណូលទាប ឬមធ្យម អ្នករស់នៅក្នុងសហគមន៍ដែលខ្វះខាត ឬផ្ទុកលើសទម្ងន់ និងមិនសូវមានសេវា
- ✓ ស្ថាប័នរដ្ឋាភិបាល រួមទាំងទីភ្នាក់ងាររៀបចំផែនការក្នុងតំបន់ កុលសម្ព័ន្ធដែលទទួលស្គាល់ដោយសហព័ន្ធ កុលសម្ព័ន្ធដែលទទួលស្គាល់ដោយរដ្ឋ ឬកុលសម្ព័ន្ធដែលទទួលយល់ព្រមដោយរដ្ឋ
- ✓ ក្រុមបុគ្គលដែលអាចរងផលប៉ះពាល់យ៉ាងជាក់លាក់ និងគួរឱ្យកត់សម្គាល់ដោយដំណើរការនីតិវិធី

មានតែភាគីដែលទទួលបានមុខងារជាអន្តរការីក្នុងដំណើរការនីតិវិធីរបស់ DPU ឬ EFSB ប៉ុណ្ណោះដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ។

បុគ្គលម្នាក់ៗមិនមានសិទ្ធិទទួលបានមូលនិធិជំនួយទេ។

# លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបានមូលនិធិជំនួយ

1. ថាតើ បេក្ខជនខ្វះខាតធនធានហិរញ្ញវត្ថុដែរឬទេ

2. ថាតើអ្នកដាក់ពាក្យសុំធ្លាប់បានធ្វើអន្តរាគមន៍ក្នុងដំណើរការនីតិវិធី ឬបានចូលរួមចាប់តាំងពីការបង្កើតកម្មវិធី។ ក្រុងដែលមានចំនួនប្រជាជន <7,500 នាក់ត្រូវបានលើកលែងពីលក្ខណៈវិនិច្ឆ័យនេះ

3. របៀបដែលអ្នកដាក់ពាក្យសុំចូលរួមចំណែកយ៉ាងសំខាន់ដល់ដំណើរការនីតិវិធី

4. ថាតើអ្នកដាក់ពាក្យសុំផែនការដែលអាចសម្រេចបាន ដោយមានហេតុផល និងបានបញ្ជាក់យ៉ាងច្បាស់លាស់សម្រាប់ការចូលរួមក្នុងដំណើរការនីតិវិធី

5. ថាតើអ្នកដាក់ពាក្យសុំមានទស្សនវិស័យតែមួយគត់ដែលមិនត្រូវបានតំណាងគ្រប់គ្រាន់ដោយភាគីផ្សេងទៀតក្នុងដំណើរការនីតិវិធី

6. ចំនួនទឹកប្រាក់ និងភាពសមហេតុផលនៃមូលនិធិដែលបានស្នើសុំ និងការចំណាយថវិកាដែលបានស្នើឡើង

លក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបាន 1 និង 2 គឺបានមកពី G.L. c. 164, § 149 (b) នៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024

# កម្មវិធីជំនួយគាំទ្រអន្តរាគមន៍របស់ DPU និង EFSB

## ពេលវេលាការដាក់ពាក្យសុំជំនួយ និងការសម្រេចចិត្ត

- ទម្រង់ពាក្យសុំគួរតែត្រូវបានដាក់ជូនមិនលើសពីថ្ងៃផុតកំណត់ដើម្បីធ្វើអន្តរាគមក្នុងដំណើរការនីតិវិធីរបស់ DPU ឬ EFSB ដូចដែលបានបញ្ជាក់នៅក្នុងសេចក្ដីជូនដំណឹងនៃដំណើរការនីតិវិធី
- ពាក្យសុំត្រូវបានពិនិត្យឡើងវិញសម្រាប់ភាពពេញលេញក្នុងរយៈពេល 14 ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួល
- នាយក DPP នឹងផ្ដល់ជំនួយហិរញ្ញវត្ថុទៅតាមលក្ខខណ្ឌ ប្រសិនបើជំនួយហិរញ្ញវត្ថុមិនត្រូវបានផ្ដល់រហូតដល់ស្ថានភាពអន្តរាគមត្រូវបានផ្ដល់
- សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរអំពីការអនុម័តជំនួយហិរញ្ញវត្ថុនិងការសម្រេចចិត្តទូទាត់ដល់អ្នកដាក់ពាក្យទាំងអស់នឹងត្រូវបានធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីថ្ងៃផុតកំណត់ដើម្បីដាក់ពាក្យសុំមូលនិធិអន្តរាគម
- ការសម្រេចចិត្តរបស់នាយក DPP ថាតើត្រូវអនុម័តការផ្ដល់ជំនួយហិរញ្ញវត្ថុគឺជាការសម្រេចចុងក្រោយ ហើយមិនស្ថិតក្រោមការពិនិត្យបន្ថែមទៀតទេ (ផ្នែកទី 82 (i))

## ការផ្ដល់មូលនិធិជំនួយ

- ជំនួយហិរញ្ញវត្ថុសម្រាប់ដំណើរការ DPU ឬ EFSB តែមួយមិនគួរលើសពី $150,000 សម្រាប់ភាគីនីមួយៗ និង $500,000 សរុបសម្រាប់ដំណើរការតែមួយ
- ការផ្ដល់មូលនិធិអាចត្រូវបានបង្កើនលើសពីអតិបរមានេះលើការបង្ហាញពីបុព្វហេតុល្អ ឬប្រសិនបើបញ្ហាមិនជួបប្រទះ បញ្ហាថ្មី ឬបញ្ហាស្មុគស្មាញកើតមានឡើង
- DPU DPP នឹងពិចារណាពីសក្ដានុពលសម្រាប់អន្តរាគមដែលទទួលបានមូលនិធិជំនួយដើម្បីចែករំលែកការចំណាយនៅពេលដែលមុខងារស្របគ្នា

# ទម្រង់ពាក្យសុំជំនួយហិរញ្ញវត្ថុ

1. សេចក្តីថ្លែងការណ៍ដែលបង្ហាញពីដែនកំណត់ និងវិសាលភាពនៃការចូលរួមរបស់បេក្ខជនដែលរំពឹងទុកនៅក្នុងដំណើរការនីតិវិធី។ ការពិពណ៌នាអំពីរបៀបដែលមូលនិធិនឹងត្រូវបានប្រើប្រាស់ និងរបៀបដែលអ្នកដាក់ពាក្យស្នើសុំរំពឹងថានឹងធ្វើការរួមចំណែកយ៉ាងសំខាន់

2. ការប៉ាន់ស្មានលើការចំណាយ និងថ្លៃឈ្នួលមេធាវី អ្នកប្រឹក្សា និងអ្នកជំនាញដែលរំពឹងទុក (រួមទាំងអ្នកជំនាញសហគមន៍) និងការចំណាយផ្សេងទៀតសម្រាប់ការចូលរួមក្នុងដំណើរការនីតិវិធី

3. ព័ត៌មានសាវតាអំពីមេធាវី ទីប្រឹក្សា អ្នកជំនាញ (រួមទាំងអ្នកជំនាញសហគមន៍) ដែលអ្នកដាក់ពាក្យស្នើសុំមានគម្រោងរក្សាទុក និងសេវាកម្មដែលនីមួយៗនឹងផ្តល់

4. សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីជំហរ និងលក្ខណៈផលប្រយោជន៍ដែលអ្នកដាក់ពាក្យសុំតំណាង និងសេចក្តីសង្ខេបនៃសំណួរ និងកង្វល់ដែលបានលើកឡើងក្នុងអំឡុងពេលកិច្ចប្រជុំការចូលរួមមុនពេលដាក់ពាក្យ ប្រសិនបើអាចអនុវត្តបាន

5. ចំនួនទឹកប្រាក់ដែលកំពុងស្វែងរក

6- ការពិពណ៌នាសង្ខេបអំពីអង្គការដែលស្វែងរកជំនួយហិរញ្ញវត្ថុ លក្ខណៈនៃការងាររបស់អង្គការ និងសេចក្តីសង្ខេបដើម្បីបង្ហាញថាការចូលរួមក្នុងដំណើរការនីតិវិធីនឹងបង្កការលំបាកផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរ

7. លេខឯកសារ និងចំណងជើងសំណុំរឿងដំណើរការ DPU និង EFSB ពីមុនដែលអ្នកដាក់ពាក្យសុំបានចូលរួម

8. ក្រុមបុគ្គលដែលមិនរួមបញ្ចូលគ្នាដែលដាក់ពាក្យសុំជំនួយគួរតែបញ្ជូនលិខិតបញ្ជាក់ដោយខ្លួនឯងដែលរួមមានឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលទាំងអស់នៅក្នុងក្រុមដែលស្នើសុំមូលនិធិ ចំនួនអ្នកស្ម័គ្រចិត្ត ឬអ្នកគាំទ្របន្ថែមប្រសិនបើអាចអនុវត្តបាន និងរៀបរាប់រឿងដើម្បីបង្ហាញពីកម្រិតការលំបាកផ្នែកហិរញ្ញវត្ថុ។

តម្រូវការនៃទម្រង់ពាក្យសុំជំនួយ 1, 2, 3 គឺបានមកពី G.L. c. 164, § 149 (d) នៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024

# សំណើសុំការទូទាត់ជំនួយហិរញ្ញវត្ថុ និងលក្ខខណ្ឌតម្រូវនៃ

សំណើសុំការទូទាត់ជំនួយហិរញ្ញវត្ថុអាចត្រូវបាន**ដាក់ជូនជាមុន**មុនពេលការចំណាយត្រូវបានកើតឡើង នៅពេលបង្ហាញពីការលំបាកផ្នែកហិរញ្ញវត្ថុ

សំណើនឹងរួមបញ្ចូលព័ត៌មានជាមូលដ្ឋានអំពីអ្នកទទួលជំនួយ (ឧទាហរណ៍ឈ្មោះ អាសយដ្ឋាន ព័ត៌មានលម្អិតទំនាក់ទំនង) ឯកសារដំណើរការ # និងចំណងជើងករណី ចំនួនទឹកប្រាក់ជំនួយដែលបានផ្តល់ មូលនិធិដែលទទួលបានរហូតមកដល់បច្ចុប្បន្ន

ការទូទាត់កម្រិតខ្ពស់គួរតែរួមបញ្ចូលព័ត៌មានលម្អិតអំពីការចំណាយដែលបានគ្រោងទុកជាមួយនឹងការពិពណ៌នាសង្ខេប និងវិក្កយបត្រ។ ការទូទាត់ប្រាក់ជំនួយនឹងត្រូវបានធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការទទួលបានសំណើ។

ការទូទាត់ជំនួយហិរញ្ញវត្ថុអាចត្រូវបាន**ស្នើសុំជាសំណង**លើការចំណាយជាច្រើនដងក្នុងអំឡុងពេលដំណើរការ ខណៈពេលដែលការចំណាយត្រូវបានកើតឡើង

សំណើនឹងរួមបញ្ចូលព័ត៌មានជាមូលដ្ឋានអំពីអ្នកទទួលជំនួយ (ឧទាហរណ៍ឈ្មោះ អាសយដ្ឋាន ព័ត៌មានលម្អិតទំនាក់ទំនង) ឯកសារដំណើរការ # និងចំណងជើងករណី ចំនួនទឹកប្រាក់ជំនួយដែលបានផ្តល់ មូលនិធិដែលទទួលបានរហូតមកដល់បច្ចុប្បន្ន

ការទូទាត់សំណងគួរតែរួមបញ្ចូលព័ត៌មានលម្អិតអំពីមូលនិធិដែលបានចំណាយ និងសកម្មភាពដែលធ្វើឡើងជាមួយនឹងមូលនិធិ បង្កាន់ដៃ និងភស្តុតាងអំពីសុពលភាពរបស់ព័ត៌មានដែលបានដាក់ស្នើ។ ការទូទាត់ជំនួយហិរញ្ញវត្ថុនឹងត្រូវបានធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការទទួលបានសំណើ។

## លក្ខខណ្ឌតម្រូវនៃអនុលោមភាព

ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការបញ្ចប់ដំណើរការ អ្នកទទួលជំនួយត្រូវតែបញ្ជូនរបាយការណ៍ដែលមានព័ត៌មានលម្អិតនៃ

(i) របៀបដែលមូលនិធិត្រូវបានប្រើប្រាស់

(ii) ការចូលរួមចំណែកយ៉ាងសំខាន់របស់ម្ចាស់ជំនួយក្នុងដំណើរការនីតិវិធី ហើយនិង

(iii) បង្ហាញថាការចូលរួម និងការប្រើប្រាស់មូលនិធិរបស់ពួកគេមិនបានពន្យារពេលដំណើរការទេ។

# ការប្រើប្រាស់មូលនិធិជំនួយហិរញ្ញវត្ថុដែលមានសិទ្ធិទទួលបាន និងមិនមានសិទ្ធិទទួលបាន

## ការប្រើប្រាស់មូលនិធិជំនួយដែលមានសិទ្ធិទទួលបាន (G.L.c. 164, § 149 (g))

- រក្សាទីប្រឹក្សាផ្នែកច្បាប់ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ អ្នកជំនាញរួមទាំងអ្នកជំនាញសហគមន៍ និងអ្នកប្រឹក្សាដែលមានសមត្ថភាព
- រហូតដល់ 10% អាចប្រើប្រាស់លើការចំណាយអភិបាលកិច្ចក្រៅពីផ្នែកច្បាប់ និងការចំណាយអភិបាលកិច្ចក្រៅពីលើអ្នកជំនាញ និងលើចំណាយរដ្ឋបាលមិនជាទីប្រឹក្សាយោបល់ដែលពាក់ព័ន្ធនឹងការចូលរួម

## ការប្រើប្រាស់មូលនិធិជំនួយហិរញ្ញវត្ថុមិនមានសិទ្ធិទទួលបាន

- ការទិញ ឬការជួលគ្រឿងបរិក្ខារ
- ការបញ្ចុះបញ្ចូលផ្នែកគោលនយោបាយទាក់ទងនឹងគម្រោង
- ការផ្សាយពាណិជ្ជកម្ម ឬការចំណាយលើទីផ្សារ ដើម្បីផ្សព្វផ្សាយជាសាធារណៈនូវទស្សនៈរបស់អ្នកដាក់ពាក្យស្នើសុំលើដំណើរការនីតិវិធី
- ការចំណាយដើម្បីប្ដឹងឧទ្ធរណ៍ការសម្រេចចិត្តចុងក្រោយរបស់ DPU ឬ EFSB នៅក្នុងដំណើរការនីតិវិធី

# កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយកម្មវិធី និងការតាមដានការវាស់ស្ទង់

## G.L. c. 164, § 149 (k) តម្រូវឱ្យនាយក DPP បង្កើត៖

ឯកសារអប់រំដែលអាចចូលប្រើបាន ពហុភាសា និងភាសាធម្មតាតាមគេហទំព័រ រួមទាំងទម្រង់បែបបទ និងគំរូ ដើម្បីអប់រំអ្នកទទួលជំនួយនាពេលអនាគត និងសាធារណជនអំពីកម្មវិធី

កម្មវិធីផ្សព្វផ្សាយតាមអនឡាញនិង ដោយផ្ទាល់ដ៏ល្អ ដើម្បីអប់រំអ្នកទទួលជំនួយហិរញ្ញវត្ថុនាពេលអនាគត និងសាធារណជនអំពីឱកាសផ្តល់មូលនិធិ

## G.L. c. 164, § 149 (j) តម្រូវឱ្យ DPP៖

រៀបរាប់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនអំពីសកម្មភាពទាំងអស់របស់មូលនិធិ ឧទាហរណ៍ ប្រាក់ដែលបានផ្តល់រង្វាន់ ចំនួនអ្នកដាក់ពាក្យសុំ និងផលប៉ះពាល់របស់អ្នកអន្តរាគមន៍ និងការរួមចំណែកដល់ដំណើរការនីតិវិធីរបស់ DPU និង EFSB។

## ផ្នែកទី 136 នៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យ DPP៖

ពិនិត្យមើលកម្មវិធីឡើងវិញមិនឱ្យលើសពីថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2029 និងផ្តល់ឱកាសផ្តល់យោបល់ជាសាធារណៈដើម្បីកំណត់ថាតើកម្មវិធី និងបទប្បញ្ញត្តិដែលត្រូវគ្នាត្រូវធ្វើវិសោធនកម្មដែរឬទេ។

# សំណើសុំមតិយោបល់

- តើលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបានបន្ថែមអ្វីខ្លះគួរតែត្រូវបានពិចារណាក្នុងករណីដែលមាន ដើម្បីកំណត់ការបែងចែកមូលនិធិដល់អ្នកទទួលជំនួយនាពេលអនាគត?
- តើលក្ខណៈវិនិច្ឆ័យអ្វីខ្លះគួរតែត្រូវបានអនុវត្តដើម្បីកំណត់ថាតើអន្តរការីអាចចែករំលែកការចំណាយតាមរយៈការសហការជាមួយភាគីផ្សេងទៀតក្នុងដំណើរការនីតិវិធីដើម្បីលើកទឹកចិត្តដល់ប្រសិទ្ធភាពនៃការចំណាយ និងកាត់បន្ថយការងារមិនចាំបាច់?
- តើនៅពេលណាដែលអន្តរការីដែលគាំទ្រដោយមូលនិធិគួរតែអាចទទួលបានមូលនិធិដែលលើសពីកម្រិតមូលនិធិអតិបរមានៃ $150,000 សម្រាប់ដំណើរការនីតិវិធី? តើកាលៈទេសៈអ្វីខ្លះដែលអាចមានលក្ខណៈគ្រប់គ្រាន់ជា “បញ្ហាថ្មី ប្រលោមលោក ឬស្មុគស្មាញ” ដែលអាចតម្រូវឱ្យមានមូលនិធិបន្ថែម?
- តើធនធានព័ត៌មានអ្វីខ្លះគួរតែមាននៅលើគេហទំព័រ DPU DPP សម្រាប់អ្នកដែលដាក់ពាក្យសុំមូលនិធិអន្តរាគមន៍?
- តើការផ្តល់ជំនួយហិរញ្ញវត្ថុនេះគួរតែមានចំនួនកម្រិតខ្ពស់បំផុត(ឧទាហរណ៍75%)ដែលអាចផ្តល់ជាមុនសម្រាប់អ្នកដែលមានបញ្ហាហិរញ្ញវត្ថុ ឬត្រូវតែសម្រេចតាមករណីមួយទៅមួយ?

# សំណួរ ចម្លើយ ការពិភាក្សា

# កិច្ចប្រជុំនឹងបន្តនៅម៉ោង 7:40 p.m.

# ផែនការអត្ថប្រយោជន៍សហគមន៍ (CBP) ក្នុងការកំណត់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពល

## ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន (EEA)
## ការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន (OEJE)

ខែមេសា ឆ្នាំ 2025

Draft: For Policy Development Purposes

# ការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន

- **ការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន (OEJE) នៃរដ្ឋ Massachusetts ទទួលខុសត្រូវក្នុងការអនុវត្តគោលការណ៍យុត្តិធម៌ផ្នែកបរិស្ថាន ដូចមានកំណត់ក្នុងផ្នែកទី 62 នៃជំពូកទី 30 ក្នុងការប្រតិបត្តិការរបស់ការិយាល័យ និងទីភ្នាក់ងារនីមួយៗក្រោមការិយាល័យប្រតិបត្តិ។ គោលការណ៍យុត្តិធម៌ផ្នែកបរិស្ថានគឺ៖**
  1. ការចូលរួមប្រកបដោយអត្ថន័យរបស់ប្រជាជនទាំងអស់ទាក់ទងនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយបរិស្ថាន រួមទាំងគោលនយោបាយបម្រែបម្រួលអាកាសធាតុ និង
  2. បែងចែកថាមពល ផលប្រយោជន៍ និងបន្ទុកដល់បរិស្ថានដោយស្មើភាពគ្នា។

- **ច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 បានបញ្ចូល OEJE ទៅក្នុងលក្ខន្តិកៈដែលមានអាណត្តិជាក់លាក់ដើម្បីបង្កើតស្តង់ដា និងគោលការណ៍ណែនាំដែលគ្រប់គ្រងការប្រើប្រាស់ជាសក្តានុពល និងភាពអាចអនុវត្តបាននៃផែនការ និងកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ និងការវិភាគផលប៉ះពាល់សរុប។**

# ពាក្យគន្លឹះដែលត្រូវដឹង

- **យុត្តិធម៌បរិស្ថាន (EJ) ៖** យុត្តិធម៌បរិស្ថានគឺជាការការពារដោយស្មើភាពគ្នា និងការចូលរួមប្រកបដោយអត្ថន័យរបស់ប្រជាជន និងសហគមន៍ទាំងអស់ទាក់ទងនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តក្នុងវិស័យថាមពល ការប្រែប្រួលអាកាសធាតុ និងច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយបរិស្ថាន និងការចែកចាយថាមពល និងអត្ថប្រយោជន៍ និងបន្ទុកដល់បរិស្ថានដោយស្មើភាពគ្នា។

- **សហគមន៍ដែលជួបការលំបាក៖** សហគមន៍មួយឬច្រើន ដែលជួបប្រទះនូវបញ្ហាបរិស្ថាន អាកាសធាតុ សុខភាពសាធារណៈ និងបន្ទុកសេដ្ឋកិច្ចលើសសមាមាត្រ។

- **ការចូលរួមប្រកបដោយអត្ថន័យ៖** ការចូលរួមរបស់សាធារណជននៅដើមដំបូង ជាបន្តបន្ទាប់ ដែលអាចធ្វើទៅបាន និងប្រកបដោយសមត្ថភាពផ្នែកវប្បធម៌ ដែលអនុញ្ញាតឱ្យមានការចូលរួមពីសហគមន៍ ដើម្បីជូនដំណឹងអំពីការសម្រេចចិត្ត និងគោលនយោបាយសាធារណៈ។

- **បម្លាស់ប្តូរប្រកបដោយយុត្តិធម៌៖** ការផ្លាស់ប្តូរសេដ្ឋកិច្ច និងសង្គមទៅរកថាមពលស្អាត ដែលផ្តោតលើសមធម៌ យុត្តិធម៌បរិស្ថាន កម្មករ និងសហគមន៍ជួរមុខ។

# តើផែនការអត្ថប្រយោជន៍សហគមន៍ជាអ្វី?

ផែនការអត្ថប្រយោជន៍សហគមន៍បង្ហាញពី**ការប្តេជ្ញាចិត្ត**ដោយអ្នកអភិវឌ្ឍគម្រោងដើម្បីផ្តល់អត្ថប្រយោជន៍ដ៏មានអត្ថន័យដែលអាចវាស់វែងបានដល់សហគមន៍ ជាពិសេសអ្នកដែលជួបការលំបាកពីដើមមក បន្ទុកខ្លាំង និងមិនសូវទទួលបានសេវា។

អត្ថប្រយោជន៍សហគមន៍គឺ**ជាលទ្ធផលជាក់ស្តែង និងយូរអង្វែង**ដែលផែនការផ្តល់ជូនឆ្លើយតបទៅនឹងអាទិភាព តម្រូវការ និងកង្វល់របស់សហគមន៍ដែលទទួលរងឥទ្ធិពល។

# CBP ធៀបនឹង CBA

| ផែនការអត្ថប្រយោជន៍សហគមន៍ (CBP) | កិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ (CBA) |
|---|---|
| • ផែនការដែលអាចអនុវត្តបាន**មិនមែនតាមផ្លូវច្បាប់** ដែលបង្កើតឡើងដោយអ្នកអភិវឌ្ឍន៍គម្រោង ដោយពិគ្រោះយោបល់ជាមួយសហគមន៍ដែលទទួលរងឥទ្ធិពល<br>• សេចក្តីសង្ខេបនៃ**ការចូលរួមរបស់សហគមន៍**<br>• គូសបញ្ជាក់ពី**ការប្តេជ្ញាចិត្ត**របស់អ្នកអភិវឌ្ឍន៍ចំពោះតម្រូវការរបស់សហគមន៍ (ឧទាហរណ៍ លំនៅឋានដែលមានតម្លៃសមរម្យ ការបង្កើតការងារ បង្កើនលទ្ធភាពទទួលបានកន្លែងបៃតង ។ល។)<br>• **ចាប់ផ្តើមការអភិវឌ្ឍ**ក្នុងអំឡុងពេលដំណើរការមុនដាក់ពាក្យសុំការអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំងគ្រឿងបរិក្ខារថាមពល (EFSB) **ឬពីក្រុង** | • កិច្ចព្រមព្រៀង**ចងកាតព្វកិច្ចស្របច្បាប់**ដែលបានចរចាររវាងសាលាក្រុងឬអង្គការសហគមន៍ និងអ្នកអភិវឌ្ឍន៍<br>• គូសបញ្ជាក់ពី**អត្ថប្រយោជន៍ជាក់លាក់**ដែលអ្នកអភិវឌ្ឍន៍នឹងផ្តល់ដល់សហគមន៍<br>• **អាចអនុវត្តបាននៅក្នុងតុលាការ** ដែលផ្តល់ឱ្យសហគមន៍នូវការធានាដ៏រឹងមាំថាអ្នកអភិវឌ្ឍន៍នឹងអនុវត្តតាមការប្តេជ្ញាចិត្តរបស់ពួកគេ<br>• CBA **អាចជាលទ្ធផលរបស់** CBP |

# មូលហេតុដែល CBP មានសារៈសំខាន់

- តាមប្រវត្តិសាស្ត្រ សហគមន៍ដែលជួបការលំបាកបានទទួលរងនូវហេដ្ឋារចនាសម្ព័ន្ធថាមពលឥន្ធនៈហ្វូស៊ីល និងការបំពុលដែលពាក់ព័ន្ធ ខណៈដែលខ្វះលទ្ធភាពទទួលបានអត្ថប្រយោជន៍។

- **CBP កំណត់ឡើងវិញនូវការអភិវឌ្ឍផែនការថាមពលស្អាត ដើម្បី៖**
  1. សំឡេងសហគមន៍កណ្ដាល
  2. កាត់បន្ថយគ្រោះថ្នាក់ និងការផ្លាស់ទីលំនៅ
  3. បង្កើតទ្រព្យសម្បត្តិនិងសមត្ថភាពក្នុងស្រុក
  4. កាត់បន្ថយហានិភ័យផ្នែកច្បាប់ នយោបាយ និងសហគមន៍សម្រាប់អ្នកអភិវឌ្ឍន៍

# ដំណើរការចូលរួមពីសហគមន៍ – គោលការណ៍ស្នូល

- ✓ **ចាប់ផ្តើមដំបូង៖** សហគមន៍គួរតែចូលរួមឱ្យបានឆាប់នៅក្នុងដំណើរការអភិវឌ្ឍន៍គម្រោង—មុនពេលការសម្រេចចិត្តបានបញ្ចប់—ដើម្បីបង្កើតលទ្ធផលប្រកបដោយអត្ថន័យ ។
- ✓ **ធានាបាននូវបរិយាបន្ន៖** សហគមន៍ដែលខ្វះខាតដែលទទួលរងផលប៉ះពាល់ និងអ្នកដែលបាត់បង់ឱកាសជាប្រវត្តិសាស្ត្រគួរតែទទួលបានការផ្តល់អាទិភាព។ ការចូលរួមគួរតែជាលទ្ធភាពដែលអាចទទួលបាន និងប្រកបដោយសមធម៌ ។
- ✓ **កសាងទំនុកចិត្តតាមរយៈតម្លាភាព៖** ការប្រាស្រ័យទាក់ទងបើកចំហ និងស្មោះត្រង់អំពីគោលដៅ ហានិភ័យ អត្ថប្រយោជន៍ និងដែនកំណត់ជំរុញការជឿទុកចិត្ត និងភាពជឿជាក់រវាងសហគមន៍ និងអ្នកគាំទ្រគម្រោង។
- ✓ **គោរពចំណុចពាក់ព័ន្ធផ្នែកវប្បធម៌៖** កិច្ចខិតខំប្រឹងប្រែងក្នុងការចូលរួមគួរតែឆ្លុះបញ្ចាំង និងគោរពភាសា គុណតម្លៃ ប្រវត្តិសាស្ត្រ និងរចនាប័ទ្មទំនាក់ទំនងរបស់សហគមន៍ ដើម្បីឱ្យមានអត្ថន័យ និងអាចទទួលបាន។
- ✓ **បង្កើតការចូលរួមដែលបន្តមាន៖** ការចូលរួមមិនមែនជាប្រអប់ធីកទេ-វាគឺជាការសន្ទនាជាបន្តបន្ទាប់ម្តងហើយម្តងទៀតទៅវិញទៅមក ពេញមួយការអភិវឌ្ឍគម្រោង ការកំណត់ទីតាំង និងការអនុញ្ញាត។
- ✓ **បង្កប់គណនេយ្យភាព៖** បង្កើតយន្តការដើម្បីតាមដានវឌ្ឍនភាព គោរពការប្តេជ្ញាចិត្ត និងផ្តល់សិទ្ធិអំណាចដល់ការត្រួតពិនិត្យរបស់សហគមន៍។

# ជំហានបន្តបន្ទាប់គ្នា៖ តើធ្វើដូចម្តេចដើម្បីបង្កើត CBP ដ៏រឹងមាំ

នោះបើជាសហគមន៍នីមួយៗខុសគ្នា ហើយអាចត្រូវការតម្រូវការផ្សេងគ្នាក៏ដោយ ក៏រចនាសម្ព័ន្ធនេះធានានូវវិធីសាស្ត្រមួយប្រកបដោយភាពទៀងទាត់ចំពោះតម្លាភាព បរិយាបន្ន និងគណនេយ្យភាព។ ជំហាននីមួយៗមានគោលបំណងឱ្យមានភាពបត់បែនគ្រប់គ្រាន់ដើម្បីសម្របខ្លួនទៅនឹងបរិបទក្នុងស្រុក ខណៈពេលដែលតឹងរឹងគ្រប់គ្រាន់ដើម្បីធានាថាដំណើរការនាំទៅរកអត្ថប្រយោជន៍សហគមន៍ពិតប្រាកដ និងអាចវាស់វែងបាន។

1. ការផ្តួចផ្តើមភាគីពាក់ព័ន្ធ និងការកំណត់អត្តសញ្ញាណសហគមន៍
2. បង្កើតផែនការចូលរួមពីសហគមន៍
3. ធ្វើការផ្សព្វផ្សាយដល់សហគមន៍មុនពេលដាក់ឯកសារ
4. បង្កើតការប្តេជ្ញាចិត្តចំពោះអត្ថប្រយោជន៍រួមគ្នា
5. បង្កើត CBP សាធារណៈជាលាយលក្ខណ៍អក្សរ
6. បង្កើតគណនេយ្យភាពជាផ្លូវការ

# ការបំប្លែងការប្តេជ្ញាចិត្តទៅជាសកម្មភាព

## CBP ដែលមានរចនាសម្ព័ន្ធយ៉ាងល្អ ត្រូវតែ៖

- រៀបរាប់យ៉ាងច្បាស់អំពីអត្ថប្រយោជន៍ដែលបានស្នើឡើងនីមួយៗ រួមទាំងអ្វីដែលកំពុងផ្តល់ជូន និងអ្នកដែលវាមានបំណងបម្រើ។
- ផ្តល់ពេលវេលាច្បាស់លាស់សម្រាប់ការផ្តល់លទ្ធផល ស្របតាមដំណាក់កាលគម្រោង (ពោលគឺមុនពេលការសាងសង់ ពេលសាងសង់ ពេលប្រតិបត្តិការ)។
- កំណត់អត្តសញ្ញាណភាគីទទួលខុសត្រូវសម្រាប់ការអនុវត្ត។
- គូសបញ្ជាក់ពីប្រភពមូលនិធិ និងថវិកាសម្រាប់អត្ថប្រយោជន៍នីមួយៗ ដោយផ្តល់តម្លាភាពអំពីរបៀបដែលធនធានត្រូវបានបែងចែក និងបន្តទ្រទ្រង់។
- រួមបញ្ចូលគោលដៅសំខាន់ៗរបស់ SMARTIE សម្រាប់ការប្តេជ្ញាចិត្តនីមួយៗ ដោយធានាថាគោលដៅគឺ៖ Specific (ជាក់លាក់) // Measurable (វាស់ស្ទង់បាន) // Achievable (អាចសម្រេចបាន) // Relevant (ពាក់ព័ន្ធ) // Time-Bound (ជាកាតព្វកិច្ចពេលវេលា) // Inclusive (មានបរិយាបន្ន) // Equitable (មានសមធម៌)

# សមាសធាតុនៃ CBP

1. **សេចក្តីសង្ខេបប្រតិបត្តិ៖** ទិដ្ឋភាពទូទៅនៃគម្រោង ដំណើរការចូលរួម លទ្ធផលជាអត្ថប្រយោជន៍សំខាន់ៗ និងលទ្ធផលដែលបានគ្រោងទុក។

2. **ការពិពណ៌នា និងបរិបទគម្រោង៖** សេចក្តីសង្ខេបនៃហេដ្ឋារចនាសម្ព័ន្ធថាមពលដែលបានស្នើឡើង រួមទាំងតម្រូវការសម្រាប់គម្រោង ទីតាំង ទំហំ ប្រភេទបច្ចេកវិទ្យា បន្ទាត់ពេលវេលា និងផលប៉ះពាល់ជាសក្តានុពល ។

3. **សេចក្តីសង្ខេបអំពីការចូលរួមរបស់សហគមន៍៖** ការពិពណ៌នាអំពីដំណើរការផ្សព្វផ្សាយ និងការចូលរួមដែលត្រូវបានប្រើដើម្បីអភិវឌ្ឍ CBP។ រួមបញ្ចូល៖ វិធីសាស្រ្តនៃការផ្សព្វផ្សាយ កាលបរិច្ឆេទ និងទីតាំងការប្រជុំ ការវាស់ស្ទង់ការចូលរួម ប្រធានបទសំខាន់ៗពីមតិរួមចំណែករបស់សហគមន៍ និងរបៀបប្តេជ្ញាចិត្តចំពោះអត្ថប្រយោជន៍ ក្រោយទទួលបានព័ត៌មានពីមតិកែលម្អ។ កំណត់ដៃគូដែលមានមូលដ្ឋានក្នុងសហគមន៍ ឬស្ថាប័នប្រឹក្សាយោបល់ទាំងអស់ដែលពាក់ព័ន្ធនឹងដំណើរការនេះ។

4. **អាទិភាពសហគមន៍ដែលបានកំណត់៖** សេចក្តីសង្ខេបនៃតម្រូវការ ក្តីកង្វល់ និងអាទិភាពដែលបានបង្ហាញដោយសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ។

# សមាសធាតុនៃ CBP (បន្ត)

5. **ការប្តេជ្ញាចិត្តចំពោះអត្ថប្រយោជន៍៖** បញ្ជីលម្អិតនៃការប្តេជ្ញាចិត្ត SMARTIE

6. **ក្របខ័ណ្ឌត្រួតពិនិត្យ និងគណនេយ្យភាព៖** ការពិពណ៌នាអំពីរបៀបដែលវឌ្ឍនភាពនឹងត្រូវបានតាមដាន រាយការណ៍ និងវាយតម្លៃតាមពេលវេលា រួមទាំងការកែប្រែដែលបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងមតិកែលម្អរបស់សហគមន៍។

7. **និរន្តរភាព និងផលប៉ះពាល់រយៈពេលយូរអង្វែង៖** ការពិពណ៌នាអំពីរបៀបដែលអត្ថប្រយោជន៍នឹងបន្តមានហួសពីដំណាក់កាលសាងសង់។

8. **ឧបសម្ព័ន្ធ (ប្រសិនបើមាន)៖** ឯកសារគាំទ្រដូចជាលិខិតគាំទ្រ ឯកសារចូលរួមពីសហគមន៍ លទ្ធផលស្ទង់មតិ ឬកិច្ចព្រមព្រៀងភាពជាដៃគូ។

# ឧទាហរណ៍នៃការប្តេជ្ញាចិត្តប្រកបដោយប្រសិទ្ធភាព និងអត្ថន័យ

ឧទាហរណ៍ទាំងនេះឆ្លុះបញ្ចាំងពីអាទិភាពរួមដូចជាយុត្តិធម៌ផ្នែកបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ និរន្តរភាព និងការការពារបរិស្ថាន។ ការប្តេជ្ញាចិត្តដែលបានធ្វើឡើងនឹងអាស្រ័យលើប្រភេទ និងទំហំនៃគម្រោង ផលប៉ះពាល់ដល់សហគមន៍ និងបានសម្របខ្លួនទៅនឹងបរិបទគោលដៅ និងបញ្ហាប្រឈមរបស់សហគមន៍នីមួយៗ។

| យុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន | នាយកដ្ឋានសេដ្ឋកិច្ច និងកម្លាំងការងារ |
|---|---|
| • ផែនការជួលបុគ្គលិកពីក្នុងតំបន់ជាមួយនឹងគោលដៅដែលបានកំណត់យ៉ាងច្បាស់សម្រាប់ការចូលរួមពីប្រជាជន EJ។<br>• មូលនិធិសម្រាប់ការដំឡើងម៉ូនីទ័រគុណភាពខ្យល់ និងកម្មវិធីត្រួតពិនិត្យសុខភាពបរិស្ថានដែលដឹកនាំដោយសហគមន៍។<br>• ក្រុមប្រឹក្សាយោបល់សហគមន៍ រួមទាំងអ្នកតំណាងផ្នែកការងារ កុលសម្ព័ន្ធ និងយុត្តិធម៌ផ្នែកបរិស្ថាន។ | • កិច្ចព្រមព្រៀងការងាររបស់គម្រោង (PLA)<br>• ការវិនិយោគលើការអភិវឌ្ឍកម្លាំងពលកម្ម រួមទាំងសេវាកម្មគាំទ្រសំខាន់ៗ។<br>• កម្មវិធីបង្រៀន និងបណ្តុះបណ្តាល។<br>• ការវិនិយោគលើលំនៅឋានដែលមានតម្លៃសមរម្យ។ |

# ឧទាហរណ៍នៃការប្តេជ្ញាចិត្តប្រកបដោយប្រសិទ្ធភាព និងអត្ថន័យ (បន្ត)

| ហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រពីសហគមន៍ | ការការពារបរិស្ថាន និងសុខភាពសាធារណៈ |
| --- | --- |
| • ការវិនិយោគលើការកែលម្អមធ្យោបាយដឹកជញ្ជូន និងលទ្ធភាពចូលប្រើប្រាស់ (ឧទាហរណ៍ ចំណែកផ្លូវរថយន្តក្រុង និងកន្លែងចាំរថយន្តក្រុង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈ ការកែលម្អផ្លូវថ្នល់ ផ្លូវចូលប្រើប្រាស់ជាសាធារណៈ)។<br>• ការអភិវឌ្ឍរួមគ្នាជាមួយសហគមន៍ដែលមានហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ ការពង្រីកប្រព័ន្ធផ្សព្វផ្សាយ បណ្តាញមីក្រូដែលជាកម្មសិទ្ធិរបស់សហគមន៍ ការសាកថ្ម EV សាធារណៈ EV រួម)។<br>• ការវិនិយោគលើទីតាំងសាធារណៈ និងទីតាំងជាសក្តានុពល។<br>• ការវិនិយោគនៅក្នុងមជ្ឈមណ្ឌលសហគមន៍ និងឧទ្យាន អង្គការសហគមន៍មូលដ្ឋាន សេវាសុខភាពផ្លូវចិត្ត និងការប្រើប្រាស់សារធាតុញៀន ជាដើម។ | • ការគាំទ្រកម្មវិធីប្រសិទ្ធភាពថាមពលរយៈពេលវែង ដូចជាការជួសជុលអគារដើម្បីបំពេញតាមស្តង់ដាប្រសិទ្ធភាពថាមពលខ្ពស់ ការដំឡើងបន្ទះសូឡា ឬការគាំទ្រសហករណ៍ថាមពលកកើតឡើងវិញតាមសហគមន៍។<br>• ការរួមបញ្ចូលការការពារសត្វព្រៃ និងជម្រកទៅក្នុងផែនការអភិវឌ្ឍ ដូចជាការបង្កើតច្រករបៀងសម្រាប់សត្វព្រៃ ការអភិរក្សដីសើម ឬការដាំដុះរុក្ខជាតិដើមដើម្បីស្តារប្រព័ន្ធអេកូឡូស៊ីធម្មជាតិឡើងវិញ។<br>• ប្រព័ន្ធត្រួតពិនិត្យផលប៉ះពាល់ផ្នែកបរិស្ថាន រួមទាំងគុណភាពខ្យល់ ទឹក និងដី។<br>• ការតែងតាំងមន្ត្រីអនុលោមភាពផ្នែកបរិស្ថានសម្រាប់គម្រោង។ |

# ការត្រួតពិនិត្យ និងគណនេយ្យភាព

- **CBP មានភាពរឹងមាំដូចជាប្រព័ន្ធដែលមាននៅទីកន្លែងដើម្បីតាមដាននិងវាយតម្លៃការអនុវត្តរបស់វា។ ដើម្បីរក្សាការជឿទុកចិត្តរបស់សាធារណជន និងធានាបាននូវការតាមដាន ផែនការ CBP គួរតែរួមបញ្ចូលការប្តេជ្ញាចិត្តចំពោះការរាយការណ៍ជាទៀងទាត់ប្រកបដោយតម្លាភាព និងការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយសហគមន៍។**
- **អ្នកស្នើគួរតែបង្កើតយន្តការគណនេយ្យភាពច្បាស់លាស់ដែលអាចរួមបញ្ចូល៖**
    - ➢ កាលវិភាគត្រួតពិនិត្យ និងរបាយការណ៍ ស្របតាមគោលដៅសំខាន់ៗនៃគម្រោង
    - ➢ ចំណុចទំនាក់ទំនងដែលបានកំណត់សម្រាប់សមាជិកសហគមន៍ និងស្ថាប័ននិយ័តកម្ម
    - ➢ ការរាយការណ៍អំពីវឌ្ឍនភាពជាសាធារណៈ ដែលបោះពុម្ពផ្សព្វផ្សាយយ៉ាងហោចណាស់ជារៀងរាល់ត្រីមាស និងមានជាភាសាផ្សេងៗជាច្រើន និងជាទម្រង់ដែលអាចប្រើបានដោយជនពិការ ឬ
    - ➢ ឱកាសសម្រាប់សហគមន៍ដើម្បីពិនិត្យមើលវឌ្ឍនភាពតាមរយៈគណៈកម្មាធិការប្រឹក្សាយោបល់ វគ្គស្តាប់ ឬវេទិកាផ្សេងទៀត
- **អ្នកតស៊ូមតិត្រូវបានលើកទឹកចិត្តឱ្យធ្វើជំហានបន្ទាប់ដោយចូលទៅក្នុងកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ (CBAS) ជាមួយអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍ សាលាក្រុង ឬសម្ព័ន្ធភាពដែលឆ្លុះបញ្ចាំងពីផលប្រយោជន៍ និងតម្រូវការរបស់អ្នករស់នៅដែលរងផលប៉ះពាល់។ កិច្ចព្រមព្រៀងទាំងនេះអាចជួយពង្រឹងការរំពឹងទុក បញ្ជាក់ពីតួនាទី និងផ្តល់ក្របខ័ណ្ឌច្បាប់ ឬកិច្ចសន្យាសម្រាប់ការតាមដាន។**

# សំណើសុំមតិយោបល់

- តើ EFSB គួរតែមានតួនាទីអ្វីខ្លះនៅក្នុងដំណើរការនេះ?
- តើប្រភេទផ្សេងទៀត ឬឧទាហរណ៍ជាក់លាក់នៃអត្ថប្រយោជន៍សហគមន៍អ្វីខ្លះដែលអ្នកអភិវឌ្ឍន៍ថាមពលស្អាត និងឧបករណ៍ប្រើប្រាស់អាចផ្តល់ជូន?
- គម្រោងទាមទារឱ្យជៀសវាង កាត់បន្ថយ និងបន្ថយផលប៉ះពាល់ ។ CBP គឺជាឧបករណ៍មួយដើម្បីបង្ហាញ និងចងចាំនូវការប្តេជ្ញាចិត្តទាំងនោះ។ តើឧបករណ៍ផ្សេងទៀតមានអ្វីខ្លះ?
- តើអ្វីជាឧបសគ្គខ្លះសម្រាប់អ្នកអភិវឌ្ឍន៍ថាមពលស្អាតក្នុងការអនុវត្ត CBPs/CBAs?
- តើនេះជាសំណួរមួយដែលយើងអាចសួរក្នុងអំឡុងពេលប្រជុំអ្នកពាក់ព័ន្ធទៅកាន់ទស្សនិកជនបានដែរឬទេ? ថាតើ CBPs អាចត្រូវបានអនុវត្តចំពោះគម្រោងក្រុងតូចៗដែរឬទេ?
- ក្នុងករណីភាគច្រើន CBAS នឹងបន្ថែមទៅលើការចំណាយសរុបនៃគម្រោងដែលបន្ទាប់មកត្រូវបានបញ្ជូនបន្តទៅកាន់អ្នកបង់ពន្ធ។ ដោយសារកត្តានេះ តើមានការព្រួយបារម្ភអំពីផលប៉ះពាល់ CBAs អាចមានលើសហគមន៍ដែរឬទេ?

# សំណួរទូទៅ ចម្លើយ ការពិភាក្សា

www.mass.gov/climateact

sitingboard.filing@mass.gov (DPU/EFSB)
energypermitting@mass.gov (EEA)
doer.siting.permitting@mass.gov (DOER)

## វគ្គទី 4 របស់ភាគីពាក់ព័ន្ធ

(ថ្ងៃទី 5 ខែឧសភា **ម៉ោង 5:30-8:30 p.m.** នៅ **Holyoke)៖ ការវិភាគផលប៉ះពាល់រួម លក្ខណវិនិច្ឆ័យភាពសមស្របរបស់ទីតាំងហាយប្រ៊ីដ៖ Holyoke** Heritage State Park, 221 Appleton Street, Holyoke, MA 01040

https://www.mass.gov/climateact